N° 5 A-63-1-53
Tossanavoaddey
INDOCHINE FRANÇAISE DÉPÔT LÉGAL

# ព្រះរាជាណាចក្រកម្ពុជា

## មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៥

Janvier

ខែមករា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

1952-1953
(5)

# ព្រះរាជអាណាចក្រកម្ពុជា

## មន្ទីរស្ដីកា ក្រសួងសិក្សាធិការ

## ឧស្សនាវដ្ដី សំរាប់គ្រូបង្រៀន

បញ្ជីរឿង ទំព័រ


សេចក្ដីណែនាំ ........................................ ៣

ចតុត្ថដ្ឋាន នឹង មជ្ឈិមដ្ឋានទី ២ ភាសា ........................ ១១

មជ្ឈិមដ្ឋានទី ១ ភាសា ........................ ១៩

អាទិកដ្ឋាន ភាសា ........................ ២៥

បវេច្ចណដ្ឋាន ភាសា ........................ ៣៤

កុមារដ្ឋាន ភាសា ........................ ៣៩

តែងសេចក្ដីសម្រាប់ប្រថមភូមិបំពេញវិជ្ជា ........................ ៤២

តែងសេចក្ដីសម្រាប់ប្រថមភូមិជាន់ដំបូង ........................ ៤៨

អាទិកដ្ឋាន — នព្វន្ត — រង្វាស់រង្វាល់ ........................ ៤៩

កុមារដ្ឋាន — នព្វន្ត — រង្វាស់រង្វាល់ ........................ ៥៧

បវេច្ចណដ្ឋាន — នព្វន្ត — រង្វាស់រង្វាល់ ........................ ៥៩

អាទិកដ្ឋាន — វត្ថុស្វាធ្យាយន៍ — វិធីបង្ការរោគ ........................ ៦៣

បវេច្ចណដ្ឋាន — វត្ថុស្វាធ្យាយន៍ — វិធីបង្ការរោគ ........................ ៦៧

កុមារដ្ឋាន — វត្ថុស្វាធ្យាយន៍ — វិធីបង្ការរោគ ........................ ៦៩

លោកនីតិ (គ្រប់ថ្នាក់) ........................ ៧៧

មេសូត្រ រត់មាត់ ........................ ៨៣

# សេចក្ដីណែនាំ

## អំពីបង្ហាត់កូនសិស្សឲ្យប្រើក្ដារឆ្នួនហៅថារបៀប

## “ ឡាម៉ារទីនីញែរ ”

បង្ហាត់កូនសិស្សឲ្យប្រើក្ដារឆ្នួនតាមរបៀប “ឡាម៉ារទីនីញែរ” ជាការគាបឲ្យក្មេងកុំរើកដៃជើងបានយ៉ាងល្មមសមគួរ ហើយនឹងដាស់សតិស្មារតីវាព្រមទាំងបណ្ដោយឲ្យវាធ្វើតាមចំណង់វាផង របៀបនេះគឺជាការបង្ហាត់កូនសិស្សឲ្យសរសេរព្រមគ្នាវិជ្ជាអ្វីមួយ ៗ យ៉ាងខ្លី កូនសិស្សនឹងធ្វើតាមបង្គាប់លោកគ្រូនៅលើក្ដារឆ្នួនរបស់គ្នា ៗ

អំពីប្រើក្ដារឆ្នួនក្នុងវិធីបង្ហាត់សរសេរតាមគ្រូថា កាលណាលោកគ្រូថាពាក្យអ្វីមួយម៉ាត់ហើយកូនសិស្សសរសេរពាក្យនោះ លោកគ្រូធ្វើអ្វីជាសំគាល់ ឧបមាដូចជាគោះតុឲ្យកូនសិស្សលើកក្ដារឆ្នួនទាំងអស់គ្នាឡើងល្មមឲ្យលោកគ្រូមើលឃើញច្បាស់ ពាក្យដែលវាសរសេរនោះបានដោយងាយ ពាក្យណាខុសលោកគ្រូនឹងប្រាប់ឲ្យវាកែមួយរំពេចទៅ ។

អំពីប្រើក្ដារឆ្នួនក្នុងវិធីបង្ហាត់នព្វន្ត គេធ្វើបានច្រើនចំពូកណាស់ទៅទៀត គឺឲ្យកូនសិស្សគូសគំនូរ សរសេរចំនួន ធ្វើលេខ ។ ល ។ កាល

ណាធ្វើអ្វី ៗ មួយ ៗ រួចហើយ កូនសិស្សលើកក្ដារខ្មៀនឡើងបង្ហាញលោកគ្រូ បើខុសលោកគ្រូនឹងបង្គាប់ឲ្យកែតាមទៅ ។

ប្រយោជន៍កុំឲ្យកូនសិស្សខ្វះចម្ងល់អំពីគូកនវាដែលអង្គុយជិតខាងគ្នា សូមលោកគ្រូបង្គាប់កូនសិស្សឲ្យផ្កាប់ក្ដារខ្មៀនកាលណាវាសរសេររួចហើយនោះភ្លាមទៅ លុះលោកគ្រូធ្វើអ្វីជាសំគាល់ឲ្យកូនសិស្សលើកក្ដារខ្មៀនឡើងទាំងអស់គ្នា លោកគ្រូពិនិត្យមើលការដែលក្មេងធ្វើនោះ បើឃើញក្មេងណាធ្វើខុសឲ្យវាដាក់ក្ដារខ្មៀនបន្ទាបចុះ ហើយឲ្យវាកែឬលុបសរសេរឡើងវិញ ។

ការហាត់ទាំងអស់នេះជាកិច្ចនាំឲ្យកូនសិស្សកំរើកដៃជើងហើយជាការល្អផង ពីព្រោះក្មេងវាចូលចិត្តចង់ធ្វើ វាធ្វើបានទាំងអស់គ្នា ហើយវាទំយកចិត្តទុកដាក់នឹងធ្វើកុំឲ្យខុសផ្ដេសផ្ដាសច្រើនពេក ជាការសំរេចដល់ក្មេងដទៃជាគូកនវាផង ។

អំពីបង្រៀនពង្សាវតារ ភូមិសាស្ត្រនឹងវត្ថុស្វាធ្យាយន៍ក៏លោកគ្រូបង្ហាត់ឲ្យសរសេរនឹងក្ដារខ្មៀនបានដែរ បើនិយាយរួបរួមទាំងអស់ទៅ គឺធ្វើបានគ្រប់វិជ្ជា កាលណាលោកគ្រូចង់ឲ្យកូនសិស្សឆ្លើយចំនួន ឆ្លើយថ្ងៃខែឆ្នាំ ឆ្លើយឈ្មោះអ្វីមួយ ឬចង់ឲ្យវាអធិប្បាយរៀបរាប់អំពីអ្វីយ៉ាងខ្លី ៗ ឬចង់ឲ្យវាគូរគំនូរផែនទីអ្វីមួយ ។

ធ្វើដូច្នេះលោកគ្រូនឹងជ្រាបអំពីវិធីបង្រៀនធ្វើបានយ៉ាងចំណាប់ដោយ

បង្ហាត់កូនសិស្សឲ្យសរសេរនឹងក្ដារខៀននោះ ហើយលោកគ្រូនឹងជ្រាបបាន ថាកូនសិស្សណាដែលនៅខ្សោយត្រូវបង្រៀនច្រើនជាងគេនោះផង ប៉ុន្តែ សូមលោកគ្រូប្រយ័ត្នកុំប្រើក្ដារខៀនច្រើនពេក ហើយសូមកុំប្រើក្ដារខៀនជាជំនួសការចោទសួរមែនទែននោះផង ពីព្រោះការចោទសួរមានប្រយោជន៍ អាចទម្លាប់កូនសិស្សឲ្យនិយាយបាន ឯការហាត់សរសេរនឹងក្ដារខៀននឹងទម្លាប់ក្មេងឲ្យនិយាយពុំបានទេ ដូច្នេះត្រូវប្រើក្ដារខៀនតែតាមពេលវេលា ហើយនឹងតាមការដែលគួរធ្វើប៉ុណ្ណោះ ម្យ៉ាងទៀតសូមលោកគ្រូប្រយ័ត្នឲ្យបេះសំអាតហើយឲ្យមានរបបផង គឺកុំឲ្យធ្វើទង្គុកទង្គើឮសូរខ្លាំង ១ កុំឲ្យសិស្សស្ដោះទឹកមាត់លុបក្ដារខៀន ១ ត្រូវបង្ហាត់ឲ្យលើកឲ្យដាក់ក្ដារខៀនកុំឲ្យឮសូរអ្វី ហើយឲ្យលុបក្ដារខៀនតែនឹងកំណាត់សំពត់ទទឹក គឺកំណាត់សំពត់ជ្រលក់ទឹកហើយពូតឲ្យស្រស់ទុកជាមុន កុំឲ្យក្មេងស្ដោះទឹកមាត់ផ្សើមកំណាត់សំពត់នោះ ការទម្លាប់ធ្វើដូច្នេះនឹងធ្វើបានដោយងាយហើយដោយឆាប់ណាស់ប៉ុន្តែដំបូងសូមលោកគ្រូបង្គាប់ឲ្យវាធ្វើហើយពិនិត្យត្រួតត្រាផងៗ

## និយាយអំពីក្ដារខៀនបញ្ឈរ

ក្ដារខៀនបញ្ឈរជាប្រដាប់មានប្រយោជន៍បំផុត គ្រូនឹងជៀសវាងប្រើពុំបានទេ កន្លែងណាជាសំខាន់ក្នុងមេរៀនដែលគ្រូបង្រៀនកូនសិស្សឲ្យថាមាត់ទទេគ្រូនឹងសរសេរនៅក្ដារខៀននោះផង ប្រយោជន៍ឲ្យកូនសិស្ស

មើលឃើញនឹងភ្នែក សេចក្ដីណាដែលបានស្ដាប់ឮនឹងត្រចៀក ម្យ៉ាងទៀតការសិក្សានីមួយៗ កូនសិស្សនឹងបានយល់ប្រាកដហើយនឹងធ្វើឲ្យត្រូវតាមផង លុះតែគ្រូពន្យល់ការនោះនៅក្ដារខៀនបញ្ឈរជាមុនស្រេច ធ្វើដូច្នេះកូនសិស្សនឹងឃើញសេចក្ដីផ្សេងៗ ដែលលោកគ្រូអធិប្បាយប្រៀបឧបមានោះ វានឹងយល់ដំណើរទំនងសេចក្ដីយកទៅធ្វើតាមការណាដែលលោកគ្រូដាក់ឲ្យវាធ្វើនោះ ។

ត្រូវដាក់ក្ដារខៀនបញ្ឈរនៅមុខកូនសិស្សដើម្បីឲ្យវាមើលឃើញគ្រប់គ្នា ក្ដារខៀននោះត្រូវធ្វើឲ្យបានធំគួរសម ត្រូវប្រយ័ត្នថែរក្សាក្ដារខៀននោះ គឺកាលណាក្ដារខៀនសណ្ដកចេញពីគ្នាត្រូវរិតឲ្យជាប់គ្នាវិញ កាលណាសរសេរពុំសូវជិតត្រូវលាបខ្មៅឡើងវិញ ។

## និយាយអំពីរៀនឲ្យចាំមាត់

តាំងពីដើមរៀងមកដល់ឥឡូវនេះ យើងបាននិយាយអំពីកិច្ចដែលលោកគ្រូត្រូវធ្វើដូចម្ដេចៗឲ្យបានកូនសិស្សប្រុងប្រយ័ត្ន ឲ្យបានកូនសិស្សចេះស្ដាប់ ហើយយល់សេចក្ដីដែលលោកគ្រូបង្រៀន ប៉ុន្តែនៅខាងចំណែកកូនសិស្សតើត្រូវធ្វើដូចម្ដេចខ្លះនឹងបញ្ជាក់ឲ្យលោកគ្រូឃើញថាបានស្ដាប់បានទន្ទេញបានចំណាំសេចក្ដីដែលលោកគ្រូបង្រៀននោះ ឯការចោទសួរនឹងបញ្ជាក់សេចក្ដីនេះបានតែដោយកន្ទែងផ្សេងៗហើយគ្រូច្រើន

តែខ្លះពេលនឹងចោទសួរកូនសិស្សឲ្យបានគ្រប់គ្នានោះផង  ម្យ៉ាងទៀតគួរតែកូនសិស្សចាំគ្រប់ការប្តូរគ្រប់សេចក្តីដែលលោកគ្រូបង្រៀនជាយ៉ាងល្អ-យ៉ាងខ្ជី  យ៉ាងច្បាស់ក្នុងការប្តូក្នុងសេចក្តីនោះ  នឹងធ្វើឲ្យបានប្រយោជន៍ ដូច្នេះត្រូវឲ្យកូនសិស្សទន្ទេញពាក្យមួយម៉ាត់ៗក្នុងសេចក្តីណាដែលលោកគ្រូបានពន្យល់រួចហើយ ៗ កូនសិស្សបានយល់ប្រាកដផង  ហើយឲ្យទន្ទេញសេចក្តីសង្ខេបក្នុងមេរៀនមួយ ៗ ឯការរៀនទន្ទេញឲ្យចាំមាត់នេះមានប្រយោជន៍សំខាន់ណាស់  ពីព្រោះទន្ទេញសេចក្តីដែលលោកគ្រូឲ្យរៀនពាក្យនោះជាប់តៗគ្នាហូរហែរទៅចិត្តថេរក្នុងស្មារតីកូនសិស្ស ដោយបានឮចំណាំនឹងត្រចៀកហើយបានសរសេរចំណាំនឹងដៃផង  ពីព្រោះបានជាពាក្យនោះច្រើនផង ៗ យើងបានឃើញច្បាស់ ខ្មែរចាស់ៗដែលពុំចេះអានអក្សរពុំចេះសរសេរ  ប៉ុន្តែចេះសូត្ររឿងក្នុងសាស្ត្រា ពីព្រោះបានទន្ទេញកាលគាត់នៅវត្តពីក្មេង ៗ  ម្យ៉ាងទៀតការរៀនឲ្យចាំមាត់មានប្រយោជន៍ធំនឹងជៀសវាងពុំបានដើម្បីឲ្យកូនសិស្សចាំថ្ងៃខែឆ្នាំ  ចាំ-មេលេខបូកមេលេខគុណ  បើក្មេងណាពុំចេះមេលេខនេះនឹងធ្វើលេខពុំបានឡើយ ៗ

ឯរៀនកាសាក៏ការទន្ទេញឲ្យចាំមាត់មានប្រយោជន៍ប្រសើរណាស់ដែរពីព្រោះសេចក្តីដែលសូត្រនោះអាចឲ្យកូនសិស្សចេះនិយាយបានដោយ

ស្រាយ ហើយបានត្រឹមត្រូវផង ឲ្យក្មេងចេះពាក្យច្រើនហើយចេះទំនងធ្វើសេចក្ដីផង បំណោះនេះអាចឲ្យវាចេះសរសេរហើយនឹងនិយាយបន្តិចៗម្ដងបានដោយស្រាយ ។

## និយាយអំពីកិច្ចការក្មេងសិស្ស

លោកគ្រូបញ្ជាក់បំណោះកូនសិស្សដោយឲ្យវាធ្វើកិច្ចការហើយនឹងធ្វើការហាត់សរសេរ គឺឲ្យវាឆ្លើយនឹងពាក្យសួរឬសរសេរមេរៀនអ្វីមួយដែលវាបានសូត្រ ហើយប៉ុន្តែការនេះក៏លោកគ្រូត្រូវទូន្មានកូនសិស្សឲ្យមែនទែនផង ពីព្រោះកូនសិស្សច្រើនតែធ្វើកិច្ចការនោះដោយខ្ជីខ្ជាឲ្យតែបានរួចហើយចាប់ វេលាកូនសិស្សកំពុងធ្វើកិច្ចការនោះ លោកគ្រូត្រូវដើរតាមបន្ទះតុក្រោយខ្នងវាពិនិត្យត្រួតត្រាការដែលវាធ្វើត្រង់គ្នា ប្រដៅឲ្យវាធ្វើហើយកែសេចក្ដីខុសវាផង លោកគ្រូហ៊ាប់សេចក្ដីដែលកូនសិស្សវាធ្វើខុស គឺលោកគ្រូបង្រៀនឲ្យវាធ្វើត្រឹមត្រូវឡើងផង ឲ្យវាធ្លាប់ផ្ចិតផ្ចង់ផង ដូច្នេះជាហេតុនាំឲ្យកូនសិស្សធ្វើឲ្យបានល្អត្រឹមត្រូវ សេចក្ដីនេះជាប្រយោជន៍ធំនាំឲ្យចំរើនបំណោះកូនសិស្ស ប៉ុន្តែត្រូវប្រយ័ត្នកុំឲ្យការកូនសិស្សធ្វើនោះវែងពេកឬពិបាកពេក ការហាត់សរសេរតែបួនប្រាំបន្ទាត់ដែលក្មេងធ្វើបានដោយផ្ចិតផ្ចង់ បានប្រយោជន៍ជាងកិច្ចការយ៉ាងវែងដែលក្មេងធ្វើឲ្យតែរួចពីដៃយ៉ាងធាប់ឥតប្រយ័ត្ននោះទៅវិញ ដូច្នេះត្រូវឲ្យកូនសិស្សធ្វើកិច្ចការខ្លីៗ

ប្រយោជន៍ឲ្យវាធ្វើរួចហើយនៅមានពេលសារើមើលឡើងវិញដោយសេចក្ដីប្រុងប្រយ័ត្នពិនិត្យពិចៃហើយមានស្មារតីគិតរកនឹកបានបរិបូណ៌ មុននឹងដល់កំណត់ពេលដែលលោកគ្រូដាក់ឲ្យធ្វើកិច្ចការអ្វីមួយ ៗ លោកគ្រូត្រូវឲ្យសំគាល់ដល់កូនសិស្ស ទាំងអស់គ្នាឲ្យវាសារើមើល ការដែលធ្វើនោះឡើងវិញយ៉ាងមួយ ៗ ហើយដោយពិនិត្យពិចៃផង ទោះជាធ្វើរួចក្ដីពុំរួចក្ដីក៏ត្រូវតែវាមើលឡើងវិញដែរ ហើយលោកគ្រូត្រូវបង្ខំកូនសិស្សនោះឲ្យវាស្ដាប់បង្គាប់ធ្វើតាមលោកគ្រូ ។

ឯចំណែកខាងនព្វន្តសេចក្ដីបញ្ញត្តិមុននេះ មានប្រយោជន៍ជាងគេពីព្រោះក្មេងច្រើនភាន់ច្រឡំខុសដោយធ្វើឥតគំនិត យើងនឹងនិយាយអំពីរឿងនេះទៅក្រោយទៀត ប៉ុន្តែវេលានេះសូមលោកគ្រូចាំជានិច្ច សេចក្ដីណាដែលកូនសិស្សដឹងខ្លួនវាថាជាភាន់ច្រឡំខុសហើយវាបានកែកំហុសនោះខ្លួនវាផង នេះជាការមានប្រយោជន៍ធំជាប បើលោកគ្រូប្រាប់ថាសេចក្ដីណាខុសហើយ លោកគ្រូកែកំហុសនោះនឹងខ្លួនលោក នេះជាការបណ្ដោយឲ្យកូនសិស្សខ្ជិលបួបណ្ដោយឲ្យវាឥតគំនិត ពីព្រោះវាបានដឹងមិនបានកែកំហុសនោះខ្លួនវា យើងទម្លាប់កូនសិស្សឲ្យធ្វើការដោយពិនិត្យពិចៃហើយដោយចំពោះពីខ្លួនវាផង ។

## និយាយអំពីកែកិច្ចការកូនសិស្ស

ត្រូវបង្ខំកូនសិស្សឲ្យខំធ្វើការជាដរាប ដូច្នេះត្រូវកូនសិស្សគិតរកហេតុដែលវាធ្វើខុសអ្វីនិមួយៗហើយកែកំហុសនោះនឹងខ្លួនវា យើងត្រូវបង្ខំវាឲ្យរកសេចក្តីបញ្ញាត់មកកែកំហុសនោះចេញ ។

និយាយដោយខ្លីទៅ កែកំហុសទាំងឡាយគឺជាហេតុនាំឲ្យកូនសិស្សចេះអ្វីៗដែលវាមិនដឹងនោះឡើង ហើយនាំឲ្យផ្ចិតផ្ចង់ក្នុងបំណេះរបស់វានោះផង ។

សូមលោកគ្រូកុំព្រួយធ្វើឲ្យអស់ទឹកខ្មៅក្រហមច្រើនពេក សូមគ្រាន់តែជួយកូនសិស្សឲ្យវាយល់កំហុសរបស់វាវិញបានហើយ តែអ្វីៗដែលកូនសិស្សមិនបានរៀនមិនបានយល់ផលនោះ ជាការនាំឲ្យខាតប្រយោជន៍ទាំងកូនសិស្សហើយទាំងលោកគ្រូផង ។

ល. ម៉ាធិព្វ៍

ស្រង់ពីកិច្ចសិក្សាបឋមវិជ្ជាបារាំងសែស – ខេមរ

ខែដេសម្ប្រ៍ ឆ្នាំ ១៩៣៣

ជន - ឈុំ

ឧត្តមដ្ឋាន

# ពីស្ទឹងត្រែងទៅហាណូយដោយអាកាសយាន

យើងឡើងលើយានស្រេចហើយ ម៉ាស៊ីនរោទ៍ស្លាបចក្រវិល អាកាសយានរត់បន្តិចរួចហោះឡើង ៗ យានហោះឡើងខ្ញុំស្រើបក្រៃពេកថ្លែងពុំបាន ខ្ញុំខ្លាចធ្លាក់ម្ដងប្រទះគ្រោះកាចអ្វីផ្សេង ៗ ប៉ុន្តែគ្មានអ្វីជាកម្រសោះមកដល់ខ្ញុំ ខ្ញុំប្រឹងបើកភ្នែកសម្លឹងទៅសព្វគ្រប់ពីលើអាកាសវេហាស៍ អាកាសយានចេះតែឡើងទៅលើក្នុងជំពៅមេឃ នោះពីក្រោមយើងៗឃើញទន្លេដូចខ្សែបន្ទះតូចឆ្មារក្ដីផ្ទក ស្រុកភូមិដូចជាគំនរកូនខ្ទមតូច ៗ មនុស្សប៉ុនស្រមោចគ្រាប់ទៅមក ៗ អាកាសយានហោះឥតអាក់រលងវាលរំលងព្រៃទុគ៌មបពិត យើងឆ្លងផុតសមុទ្រពពក ពីនោះយើងមើលទៅឃើញផ្លូវមួយខ្សែស្រអ័ព្ទ គឺផ្លូវដងទន្លេមេគង្គ ៗ អាកាសយានហោះឡើងខ្ពស់ទៀតឯអម្ពរ ដើម្បីរំលងកាត់ខ្នងផ្លូវភ្នំយូនដ៏ខ្ពស់ ៗ នោះពីចម្ងាយ យើងមើលទៅឃើញខៀវធំធេងវាលនោះឯងគឺសមុទ្រ យើងមើលទៅឃើញទីក្រុងថ្មីៗ ឃើញផ្លូវទាំងឡាយឆ្មារ ដូចសរសៃអម្បោះ ឃើញស្រែជាក្រឡាល្អិត ៗ ដូចក្រឡាចត្រង្គ ត្រង់ហ្នឹងហើយដែនតុងកឹង

យើងក៏ដល់ពេលអាកាសយាន គឺពេលបាច់ម៉ែ យានក៏សំយុងចុះលឿន

ដូចព្រួញ កន់ទន្គុកផែនដី យើងដល់ដំណាក់ហើយ ។

ហោគា ព្យូរ-អុំ

( ស្រង់ពីសេចក្ដីសំរ៉ាន់លោក ប. ឈុំ )

## ពន្យល់ពាក្យ

វេហាស៍ ឬ វេហា = ( ម. ថ. វេហាំ )- អាកាស–មេឃ ។

ទុគ៌ម ឬ ទុរគម = ( ម. ថ, ទុរគំ ) គុ. ដែលទៅបានដោយកម្រ

បព៌ត ឬ បរពត = ( ម. ថ. បរៈពត៌ ) ន. ភ្នំ ។

ទុគ៌មបព៌ត = ភ្នំដែលស្ងាត់ដាច់សន្ធឹងកម្រមានមនុស្សទៅដល់ ។

ស្រអ័ព្ទ ឬ ស្រអាប់ = ( ស. អព្ទ ឬ អភ្រ - ម. អព្ភ ) ងងិតជាស់ជិត

បាក់ភ្នែកពុំយល់ ។

អម្ពរ = មេឃ ឬ ពពក

ខ្ពង់ = ខ្នងភ្នំ ឬ កំពូលភ្នំ

អក្ខរាវិរុទ្ធ: ពេធ៍ (ធ៍) – ស្វាបបក្រ (បក្រ) – វេហាស៍ឬវេហា – ទ្វារ (រ)

សមុទ្ទ ឬ សមុទ្រ – ស្រអ័ព្ទ – ស្រអាប់ – បក្រគ្នមកពីពាក្យ

បតុរង្គ ( មានអង្គ ៤ )

ស្នួរបាទ. តើព្រោះអ្វីបានជាគេចូលចិត្តធ្វើដំណើរតាមអាកាសយាន ?
នៅប្រទេសយើងគេទៅខេត្តណាខ្លះ តាមអាកាសយាន ៗ

×
× ×

# ទឹកទន្លេសាបហក់មកវិញ

កាលរដូវទន្លេសាបមានសោភាពល្អមើល ៗ គេឃើញផ្ទះខ្ពស់ៗត្រង់ដែនវត្តភាពស្រស់គួរឲ្យស្រណោះស្រណោច ព្រះស្តូបស្តុកស្តម្ភព្រះបដិមាខ្លះធំសម្បើមដ៏មានព្រះភក្ត្រញញឹមក្សេមក្សាន្ត ៗ ប៉ុន្តែមានរដូវមួយដែលសោភាពរិតតែប្លែកចំឡែកទៀត គឺរដូវភ្លៀងដែលមេឃុំផ្ទន់ពេញរង្វាល់ៗ ទឹកជំនន់នៃមេគង្គផ្ទួញទឹកដៅៗមកប្រសព្វខ្សែទឹកហូរខ្លាំងក្លាំងឥតគណនា រុញខ្សែទឹកទន្លេដ៏ជាប្រធាននៃដៃទន្លេប្រសព្វឲ្យត្រឡប់ហូរចាក់ទៅទន្លេ-សាបទៅបំពេញផ្ទៃបឹងទីងលុបដីទំនាបជុំវិញ ៗ ទឹកជំនន់ឡើងលិចពេញបន្ទុកហើយក៏ត្រឡប់មកវិញ នៅខែកាសដែលទឹកត្រឡប់មកវិញនោះ គេឃើញមានបុណ្យដ៏រុងរឿង ដែលព្រះចៅផែនដីយាងចុះទៅប្រថាប់ក្នុងព្រះទីនាំងនាវា ដ៏មានទូកម៉ឺនសែនចតចោមរោមជាយសបរិវារ គឺជាបុណ្យព្រ័ត្រដែលគេបង្សន្ធិ៍កាត់ទន្លេ ហើយគេបណ្ដាប់ដោយមុខព្រះវ័ន ៗ ជំនន់នៃទន្លេមេគង្គជាជំនន់មានគុណដ៏ប្រសើរ ទឹកនោះនាំដីជាតិ

ទៅចំរើនដីដំណាំ    នឹងនាំឲ្យកើតត្រីជាលានកោដិដែលជាអាហារនៃអ្នកស្រុកកម្ពុជា ។ ជំនន់ឡើងលុបលិចរហូតដល់ព្រៃនោះនៅវេលាទឹកលិចព្រៃគេឃើញតែចុងព្រឹក្សាលេចពីទឹកប្រិម ៗ ជាឱកាសសប្បាយ នឹងគ្រាប់កាត់ព្រៃទៅបានឥតទើសទាស់ឡើយ ។

លោក ពូរ-អុំ

(ស្រង់ពីសេចក្ដីសំរាំងលោក ប. ឈុំ)

## ពន្យល់ពាក្យ

ទឹកទន្លេទាក់ = ទឹកទន្លេសាបហូរត្រឡប់មកទន្លេមេគុងវិញ ។

សារភាព = (ម.ឋ. សារៈភាព) — ភាវៈពិត - ដំណើរឬសេចក្ដីពិតសារ-

ភាពល្អ = ភាវៈឬដំណើរល្អ ។

វត្តភាព = (ម.ឋ. វត្តភាព)- វត្ត- ន. ការប្រព្រឹត្ត - មុខការ - កិច្ចដែល

គួរធ្វើ - នាទីវត្តភាព = ភាវៈគួរឲ្យស្រណោះស្រណោច ។

ស្តូប = ការរចនាដោយឥដ្ឋ — ស៊ីម៉ង្តសំរាប់បញ្ចុះធាតុ (ចេតិយ)

ស្តុកស្តម្ភ = មាំមួន

បដិមា = ព្រះពុទ្ធរូប

ផ្ញញ់ = រុញសង្កត់

ប្រថាប់ = គង់នៅ

បរិវារឬបរិពារ = អ្នកចោមរោមកំដរ ឬហែហមជាកិត្តិយស ។

ស្ពរបោទ = នៅផ្លូវណាដែលទន្លេមេគង្គហូរបាក់ទៅទន្លេសាប ។ ទឹកទន្លេសាបហក់មកវិញនៅផ្លូវណា ។ វេលានោះមានបុណ្យអ្វីជាឧឡារិកនៅទន្លេចតុម្មុខ ។ ដំនងទន្លេមេគង្គមានប្រយោជន៍ដូចម្ដេច ។

---

## មជ្ឈិមដ្ឋានទី ២

## ពិធីលើករាសី

វេលាដែលរាសីរបស់គេធ្លាក់គាប់ មានតែសេចក្ដីមិនស្រួលកើតឡើងញយៗ ទឹងធ្វើអ្វីច្រើនមិនសម្រេចក្ដីប្រាថ្នា ឬ កាលទឹងធ្វើការដែលសំខាន់ៗ នោះចង់ឲ្យសម្រេចឆុតឆាប់ទៅដូចបំណងក្ដី ឬ ប្រាថ្នាទឹងឲ្យឡើងយសសក្ដិធំជាងប្រក្រតីនោះក្ដី ពួកអ្នកដែលជឿក្បួនខ្នាតនោះ គេតែងរៀបចំធ្វើពិធីលើករាសីរបស់គេឲ្យរុងរឿងភ្លឺថ្លាឡើង ។ ការដែលធ្វើដូច្នោះទឹងយកជាពិតប្រាកដណាស់ពុំបាន ជួនកាលក៏ឃើញឲ្យផលមុតមែន ជួនកាលក៏សូន្យឈឹងទៅ តែនិស្ស័យមនុស្សយើងទេតើ កាលមានបំណងដូចម្ដេចហើយទឹងធ្វើខ្លួនឯងទៅតែម្ដងមិនកើត ក៏គោងពាក្យនេះ

រកនោះមកជួយ ក្រែងលោសមប្រកប ក៏នាំគ្នាធ្វើតៗ មកទាល់តែជាប់ទំនៀមមកដល់សព្វថ្ងៃនេះ ។

ឯរបៀបធ្វើនេះមានបែបបទផ្សេងៗពីគ្នាតាមគតិរបស់អាចារ្យជាអ្នកដើមការនាំឲ្យធ្វើ តែក៏មិនខុសឆ្ងាយគ្នាប៉ុន្មាន លើសខ្វះគ្នាបន្តិចបន្តួចប៉ុណ្ណោះ

(ស្រង់ពីសេចក្តីសំពាំងលោក ប. ណុំ )

## ពន្យល់ពាក្យ

ពិធី ឬ វិធិ = ន. (សំ. ម. វិធី) – បែបធ្វើ – របៀបកិច្ចការ ។

លើកកសី = តាំងប្រសិទ្ធិតាមក្បួនតម្រាឲ្យកសីដែលអាប់រុងរឿងឡើង

វេវចនៈ = ប្រក្រតី ធម្មតា = តាមចំណាំ – តាមទម្លាប់

សទិសសព្ទ: = រាវ (កិ.) រាវរកឲ្យឃើញ

(គុ.) វត្ថុរាវ ចានមួយរាវ

(គុ.) រងរៀវ

ពេចន៍ = (ន.) ពាក្យសំដី – ពាក្យពេចន៍ – អ្នកចេះពាក្យពេចន៍

ពេជ្រ = ត្បូងពេជ្រ – ចិញ្ចៀនពេជ្រ = ពេជ្រថ្ម......

ពេជ្ឈ = ពេជ្ឈឃាដ ឬ ឃាត (អ្នកពិឃាតមនុស្សទោស)

អក្ខរាវិរុទ្ធ = សក្តិ (សក្តិ ឬ ស័ក្តិ) រុងរឿង (រុ.) សូន្យ (ន្យ)

និស្ស័យ (ស្ស័) បែបបទ (ទ)

សួរចោទ — នៅវេលាណាដែលគេតាំងពិធីលើកពស៊ី ។

ពួកអ្នកដែលជឿពិធីនេះបានសម្រេចពិតប្រាកដដូចប្រាថ្នាឬទេ ?

ពិធីលើកពស៊ីនេះមានតាំងពីណាមក ។

## បុរសពីរនាក់ទាស់គ្នាអំពីជីកអណ្ដូង

មាននិទានមួយដំណាលថា មានបុរសពីរនាក់បបួលគ្នាទៅជីកអណ្ដូងទឹក លុះជីកទៅប្រទះឃើញមាសមួយពន្ធង គឺបុរសមួយជីកត្រូវមាត់ពន្ធងម្ខាង បុរសមួយទៀតក៏ជីកត្រូវមាត់ពន្ធងម្ខាងដែរ ហើយបានយកមាសមកចែកស្មើគ្នា នៅតែពន្ធងដែលដាក់មាសសំងចែកគ្នាមិនដាច់ស្រេចសោះ ។ ចៅមួយថាត្រូវឲ្យពន្ធងនេះមកអញ ឯចៅមួយថា អញជីកត្រូវស្មើគ្នាដែរ ម្ដេចក៏ត្រូវបានតែម្នាក់ឯង គួរបានអញផង ។ ចៅទាំងពីរប្រកែកគ្នាពុំស្រេច ទើបនាំសេចក្ដីទៅប្ដឹងដល់ចៅក្រម ៗ ជំនុំជំរះទៅថាត្រូវបំបែកពន្ធងនេះចែកគ្នា ឯចៅទាំងពីរពុំសុខចិត្តទើបចៅក្រមនាំចៅទាំងពីរ ឡើងទៅក្រាបបង្គំទូលសម្ដេចព្រះមហាក្សត្រាធិរាជដោយដំណើរនោះ ។

ព្រះអង្គមានព្រះបន្ទូលដណ្ដឹងចៅទាំងពីរថា មាសនឹងពន្ធងព្រះ

ស្តែងបានមកពីឯណា ឯចៅចាំងពីរក្រាបទូលព្រមពាក្យគ្នាថា សូមទ្រង់មេត្តាប្រោស ដ្បិតទូលព្រះបង្គំយើងខ្ញុំនេះ ទៅជីកអណ្តូងត្រូវលើពិនួងមាសព្រមគ្នា ទើបព្រះអង្គត្រាស់ដណ្តឹងសួរគេទៅទៀតថា នាព្រះស្តែងទៅជីកអណ្តូងនោះ តើអ្នកណាបបួលទៅជីកមុនគេ ទើបចៅមួយថាចៅនេះឯងបបួលទូលព្រះបង្គំជាខ្ញុំ ឯចៅមួយក៏ក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំបបួលចៅនេះមែន ទើបព្រះអង្គទ្រង់ព្រះចិន្តាពិចារណា យល់ថាចៅបបួលនោះ ត្រូវបានចំណែកលើសជាងគេ ទើបព្រះអង្គឲ្យយកមាសនោះមកចែកជាបីទៀត គឺឲ្យចែកជាបីភាគ ពីរភាគនឹងពិនួងត្រូវបានទៅចៅបបួល មួយភាគត្រូវបានទៅចៅដែលគេបបួលនោះ ។

ព្រះបរមក្សត្រទ្រង់វិនិច្ឆ័យសេចក្តីដូច្នេះ ចៅចាំងពីរក៏សុខចិត្ត ទើបក្រាបថ្វាយបង្គំលាទៅផ្ទះអាត្មាទីទៃៗ ។

( ស្រង់ពីសេចក្តីសំរាំងលោក ប. ឈុំ )

## ពន្យល់ពាក្យ

ពិនួង = ន. ពាងមួយបែបបាតនិងមាត់តូច ក្អេងធំ ( ពាងបុកណោ ) ។

ព្រះស្តែង ឬ ប្រស្តែង = អ្នក នាយ ចៅ ជា ។

ចិន្តា = ( ម. ថ. ចិណ្តា ) = សេចក្តីគិត ទ្រង់ព្រះចិន្តា គឺទ្រង់គិត ឬរិះគិត ។

វេវចនៈ ជុំនុំជំរះ = ពិគ្រោះ ពិភាក្សា ប្រឹក្សា វិនិច្ឆ័យ ។

សទិសសព្ទ := បារ គិ. បារគោចម៌ដី ។ បារ ន. បារបន្ទាប បារយំ ។

បា-បុ- ម្ចាលបា..... ។ បា-ន. មេបា គោបា......

អក្ខរាវិរុទ្ធ: បារ (រ) ភាគ (គ) សុខ (ខ) ចិត្ត ។

សួរដោយ := បុរសពីរនាក់នេះទាស់គ្នាពីដំណើរអ្វី ? ចៅក្រមកាត់សេចក្តីដូចម្តេច ។ ចៅទាំងពីរសុខចិត្តឬទេ ។ ហើយនាំគ្នាទៅប្តឹងឯណាទៀត ។ ព្រះមហាក្សត្រាធិរាជវិនិច្ឆ័យក្តីនោះដូចម្តេច ។ បុរសទាំងពីរបានភាគស្មើគ្នាឬទេ ។

---

## មជ្ឈិមដ្ឋានទី១

## រៀនមើល សរសេរតាមសូត្រ

### រឿងព្រះបទុមសុរិវង្ស

ក្នុងអតីតកាល មានស្តេចមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិនៅនគរពារាណសី ។ ទ្រង់មានព្រះរាជបុត្រាប្រាំពីរព្រះអង្គ ព្រះរាជបុត្រពៅទ្រង់ព្រះនាមព្រះបទុមសុរិវង្ស ។ ព្រះមហា

ក្សត្រិយ៍ត្រាស់ប្រើព្រាហ្មណ៍ម្នាក់ឲ្យបង្រៀនអក្សរ លេខនព្វន្ត និងមន្តវិជ្ជាផ្សេងៗ ដល់ព្រះរាជបុត្រាទាំងប្រាំពីរព្រះអង្គនេះ ។ ទ្រង់ព្រះរាជទានមហាឡិកប្រាំរយនាក់ឲ្យបំរើព្រះរាជបុត្រមួយព្រះអង្គ ១ ។

វេលានោះ ព្រះបទុមសុរិយវង្សទ្រង់មានព្យាយាមនឹងការរៀនសូត្រណាស់ទ្រង់មិនដែលយាងទៅក្រសាលសប្បាយឯណាសោះ ។ ទ្រង់បានប្រាជ្ញាប្រសព្វគ្រប់ក្បួនអក្ខរៈ ក្បួននព្វន្តវេទមន្តទាំងឡាយនឹងចំណេះការហត្ថកម្មដូចជាចំណេះការជាងដែក ជាងទង ជាងគំនូរ ជាងឈើ ជាងរចនាហើយនឹងចំណេះការស្រី ដូចជាដេរ ប៉ាក់ ត្បាញផង ។

អានពាក្យ = ព្រហ្មទត្ត — (អ.ថ ព្រំម:ទាត់) ។

បទុមសុរិយវង្ស = (អ.ថ ប៉ៈ ទុៈ មៈសុៈ រិៈយៈ វង់) ។

ពន្យល់ពាក្យ = ព្រះរាជទាន — (រ.ស) អំណោយរបស់ស្តេច

មហាឡិក = អ្នកបម្រើក្សត្រិយ៍ពីត្រឹមថ្នាក់ព្រះអង្គម្ចាស់ចុះមក ។

ក្រសាល = លេងលំហើយ (រ.ស) ស្តេចទ្រង់ក្រសាល ។

ពាក្យសួរ — ស្តេចណាសោយរាជ្យក្នុងក្រុងពារាណសី ? ព្រះបាទព្រហ្មទត្តមានព្រះរាជបុត្រប៉ុន្មានព្រះអង្គ ? ព្រះអង្គម្ចាស់ពៅទ្រង់ព្រះនាមដូចម្តេច ? ព្រះបាទព្រហ្មទត្តទ្រង់បង្គាប់ឲ្យព្រាហ្មណ៍បង្រៀនវិជ្ជាដល់ព្រះ-

រាជបុត្រាទាំងប្រាំពីរព្រះអង្គនោះដែរឬទេ ? ព្រះអង្គម្ចាស់ណាដែលទ្រង់ព្យាយាមរៀនសូត្រមិនមានធ្វេសប្រហែស ។

## រឿងព្រះបទុមសុរិយវង្ស (ត)

ឯព្រះរៀមទាំងប្រាំមួយព្រះអង្គពុំរៀនសូត្រអ្វីសោះ ទ្រង់ចេះតែក្រសាលកំសាន្តជាមួយនឹងពួកមហាទ្បឹក ៗ ទ្រង់ក្រសាលប្រផល់មាន់ ប្រផល់ត្រីក្រឹម អុកចត្រង្គ ហើយនឹងល្បែងបៀប៉ោងង ៗ ទ្រង់ឲ្យចេះរុក្ខផលាបណ្ណាកស្ត្រ ហើយបង្គាប់ឲ្យពួកមហាទ្បឹកចាប់មាន់ទារបស់អ្នកស្រែចំការយកមកធ្វើក្រយាស្ងោយសោយលៀវ ទ្រង់សេពសុរាស្រវឹង ហើយទ្រង់ប្រព្រឹត្តតាមតែព្រះទ័យ ។

បណ្ដាជនទាំងឡាយមានសេចក្ដីក្ដៅក្រហាយខ្លាំងណាស់ក៏ធ្វើបុតហ្វាយថ្វាយព្រះវររាជបិតា ប៉ុន្តែក្នុងបុតហ្វាយនោះគ្មានដាក់ព្រះនាមចំពោះព្រះរាជបុត្រណាដែលប្រព្រឹត្តអំពើអាក្រក់នោះទេ គេដាក់សរុបទាំងអស់តែម្ដង ៗ

លុះព្រះវររាជបិតាបានទតសេចក្ដីបុតហ្វាយរួចហើយ ក៏ទ្រង់ស្មានតែព្រះរាជបុត្រទាំងអស់ប្រព្រឹត្តអំពើទុច្ចរិតនោះ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យបំបរបង់ព្រះរាជបុត្រាទាំងប្រាំពីរព្រះអង្គនោះចេញពីព្រះនគរ ។

វេលានោះព្រះបទុមសុរិយវង្ស ទ្រង់មិនដោះសារៃកព្រះអង្គទេ ព្រោះទ្រង់សព្វព្រះទ័យថា កម្មផលដែលទ្រង់បានធ្វើទុកពីអតីតជាតិមក ត្រូវតែទទួលយក ដើម្បីកុំឲ្យសេសសល់ទៅអនាគតជាតិទៀត ។

## អាននិងពន្យល់ពាក្យ.–

រុក្ខផលា = (អ.ប.រុក្ខៈ ផៈ លា៉) ផ្លែឈើ ។

ក្រយាស្ងោយ = គោជនាហារសម្រាប់ស្ដេចសោយ ។

ចុតហ្វាយ = (អ.ប-ចុតម៉ាយ) សំបុត្រក្រាបពិតក្រាបទូល ។

បំបរបង់ = និរទេស, ប្រោសបោលឲ្យចេញផុតពាក់ដែន ។

អតីតជាតិ = (អ.ប. អតីតៈជាត ឬ អឌិតតជាត) ជាតិមុន, ជាតិដែលកន្លងទៅហើយ ។

អនាគតជាតិ = (អ.ប.អៈ នា៉គៈតៈជាត ឬ អនា៉គត់តៈជាត) ជាតិខាងមុខ ។

ពាក្យសួរ.= ព្រះអង្គម្ចាស់បង់ពាំងព្រាំមួយទ្រង់ប្រព្រឹត្តដូចម្ដេច ទ្រង់ក្រសាលអ្វីខ្លះ ? ព្រោះអ្វីបានជាបណ្ដាពស្ត្រកើតសេចក្ដីក្ដៅក្រហាយខ្លាំងណាស់ ? ពួកបណ្ដាពស្ត្រធ្វើដូចម្ដេច ? ព្រះវររាជបិតាត្រាស់បង្គាប់ដូចម្ដេច ? ព្រះបទុមសុរិយវង្សទ្រង់ធ្វើអំពើអាក្រក់ដូចព្រះរៀមពាំង

ប្រាំមួយដែរឬទេ ? ព្រោះអ្វីបានជាព្រះវររាជបិតាឲ្យបំបរបង់ព្រះបទុម-សុរិយវង្សដែរ ? ។

## រឿងព្រះបទុមសុរិយវង្ស (ចប់)

អំពើសុចរិត ដែលព្រះបទុមសុរិយវង្សទ្រង់បានប្រព្រឹត្តនោះ ក៏ពុំបាត់ស្ងាត់ ផ្សាយកិត្តិសព្ទទៅដល់ព្រះបាទព្រហ្មទត្តជាព្រះវររាជបិតា នោះព្រះបាទព្រហ្មទត្តមានព្រះរាជឱង្ការត្រាស់បង្គាប់ឲ្យអញ្ជើញព្រះបទុម-សុរិយវង្ស ជាព្រះរាជបុត្រពៅ ចូលទៅព្រះនគរវិញ ហើយអភិសេកឲ្យសោយរាជ្យសម្បត្តិគ្រប់គ្រងអាណាប្រជានុរាស្ត្រ ដោយទសពិធរាជធម៌ជាសុខក្សេមក្សាន្តទៅហោង ។

សុភាសិតថា ៖ អំពើល្អឬអាក្រក់ដែលគេបានធ្វើហើយ អំពើនោះមិនដែលបាត់ទៅណាឡើយ ។

### អាននិងពន្យល់ពាក្យ.-

កិត្តិសព្ទ = (អ.ថ. កិត តិសាប់) សូរសរសើរ ។

អភិសេក = (អ.ថ. អះភិសែក) ស្រោចទឹកក្រស់ទឹកស័ង្ខ ។

ទសពិធរាជធម៌ = (អ.ថ. ទៈសៈពិធៈរាជៈធ័រ) ធម៌ ១០ ប្រការ

សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតី មន្ត្រីធំ-តូចទាំងពួករាស្ត្រប្រជាឲ្យប្រព្រឹត្តផង ។

---

អាជីវកម្មដ្ឋាន

## បង្រៀនមើល – ហាត់និយាយ

### អាទិត្យទី ១.– អំពីទីក្រុង

នាម= វាំង ប្រសាទ វត្ត វិហារ ផ្ទះថ្ម ពេទ្យសាលា សាលា មន្ទីរពេទ្យការ ពេទ្យរាស៊ីន (ពេទ្យបក្រ) ឃុំផ្សារ ឃុំស្រុក ផ្សារ ថ្នល់ សួនច្បារ ម៉ាស៊ីនទឹក បង្គោលអគ្គិសនី ថ្នលយាន (យានដើរគោក) ជលយាន (យានដើរទឹក) ទាហាន គម្រូត ប៉ូលិស ។

គុណនាម= ស្អុកស្អក មាំមួន ប្រចង់ប្រាង ឆើតឆាយ ខ្ពង់ខ្ពស់ ល្វឹងល្វើយ ស្អាត ក្តៅផ្ដក ព្រោងព្រាត ស្រោងស្រឹង រៀបរៀង ត្រង់ រៀប ស្រស់ ស្រស់ត់ រងំ គ្រឿមក្បាត្ត ហ៊ុហា ពបទាប បំព្រង ល្ហាយល្ហង់ ប្រឹមប្រិយ ។

កិរិយាសព្ទ= ដើរលេង ត្រាច់ ចរ យាត្រា រត់ ទៅ មក វិញ

លក់ ស៊ី ផឹក ជិះ បរ ត្រួតត្រា ហាមឃាត់ បង្ហាញផ្លូវ នាំផ្លូវ ធ្វើការ សង់ រុះ រើ សែង រែក ទូល ដងែក ច្រៀង រាំ លេង ។

ហាត់និយាយ= អ្នកស្គាល់ទីក្រុងណាមួយទេ? នៅទីក្រុងនោះ អ្នកឃើញអ្វីខ្លះ? អ្នកឃើញផ្ទះនៅទីក្រុងយ៉ាងដូចម្ដេច? ទីក្រុងនោះគឺជាអ្វី? (ជាទីប្រជុំជំ) ទីក្រុងនឹងស្រុកស្រែប្លែកគ្នាយ៉ាងដូចម្ដេច ? ទីក្រុងធំនៃប្រទេសខ្មែរមាននាមហៅថាអ្វី? ។

## រៀនពាក្យហាត់ភាសា

### ក្រុងភ្នំពេញ

( សៀវភៅវិជ្ជាខេមរភាសា អាទិកដ្ឋានទំព័រ១២២ )

ហាត់ភាសា- អ្នកដែលទៅក្រុងភ្នំពេញឬទេ? ភ្នំពេញគឺជាអ្វី? ក្រុងភ្នំពេញនៅត្រង់កន្លែងណា? កាលពីដើមទីកន្លែងក្រុងភ្នំពេញយ៉ាងដូចម្ដេច? សព្វថ្ងៃនេះក្រុងភ្នំពេញយ៉ាងណា? បុកត្រពាំងបាត់ទៅណាអស់ទៅ? មានអ្វីជំនួសឡើង? នៅក្រុងភ្នំពេញមានគេហស្ថានជនជាតិអ្វីខ្លះ? គេហស្ថាននោះយ៉ាងដូចម្ដេច? អ្នកចង់ទៅលេងក្រុងភ្នំពេញឬទេ? ហេតុអ្វី? ។

ការហាត់សរសេរ៖ ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ

ទីក្រុងធំ – គេហស្ថាន – និម្មិត

## សរសេរតាមសូត្រ

( សៀវភៅដដែលទំព័រ១២២ ) ផ្នែកទី១ តាំងពី មានទីក្រុងតិចរហូតដល់...ឲ្យបានថ្កើងរុងរឿងឡើង , ផ្នែកទី២ តាំងពីលុបចុកត្រពាំងរហូតដល់ចប់ ។

អក្ខរាវិរុទ្ធ – រុងរឿង–ផុស – ព្រះធរណី – និម្មិត – សុទ្ធ-ចុកត្រពាំង – សុខក្សេមក្សាន្ត – គេហស្ថានឬគេហដ្ឋាន

## ហាត់តែងសេចក្ដី

ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

ទីក្រុងជាទីប្រជុំយ៉ាងដូចម្ដេច ? អ្នកឃើញអ្វីខ្លះក្នុងទីក្រុង ? គេហដ្ឋាននឹងផ្លូវថ្នល់នោះយ៉ាងដូចម្ដេច ? គេឃើញមានបណ្ដាជនយ៉ាងដូចម្ដេច ?

## អក្សរផ្ចង់

ប ប ម ហ បិ

ឃ ឃា ឃឺ ឃូ ឃួ ឃើ ឃៀ ឃែ ឃៃ ឃៅ

ចៅឃួបេះឃួប កុំឃៃឃែ កុំឃែងកុំឃាល់ ឃ្មឃារជាគ្រួ-លើឃ្មទាំងអស់ ។

## បង្រៀនពាក្យហាត់ភាសា

អាទិត្យទី ២.– អំពីទីក្រុង (ត)

នាម= ព្រះបរមរាជវាំង ព្រះករុណា · ព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះទីនាំងចន្ទឆាយា ព្រះទីនាំងភោជនីយ៍ ព្រះមហាប្រាសាទខេមរិន្ទ ព្រះដំណាក់ផែ ៗ ស្វេតច្ឆត្រ ព្រះបល្ល័ង្ករាជ្យ ព្រះខាន់រាជ្យ ព្រះទីនាំងសំរិទ្ធិវិមាន ព្រះទីនាំងសម្រាន្តភិរម្យ ៗ

គុណនាម= រុងរឿង ថ្កុំថ្កើង ប្រពៃ ស្អាត ធំ ទូលាយ ប្រសើរ ៗ

កិរិយាសព្ទ= ស្អាង ថ្វាយ គាល់បំរើ យាងទៅ គង់នៅ ផ្ទុំ សោយ ស្រង់ ទត ប្រទាន ៗ

ហាត់ភាសា– អ្នកដែលឃើញព្រះបរមរាជវាំងឬទេ ? ព្រះប-

រមាជវាំងនោះនៅឯណា? ព្រះបរមរាជវាំងនោះជាអ្វី? ក្នុងព្រះបរមរាជ-វាំងមានប្រាសាទអ្វីខ្លះ? ក្នុងព្រះរាជពិធីបុណ្យអុំទូក ព្រះករុណា យាង-ទៅគង់នៅឯណា? ព្រះករុណាជាម្ចាស់ជីវិតលើត្បូងសព្វថ្ងៃនេះ ទ្រង់-ឡើងសោយរាជ្យសម្បត្តិពីថ្ងៃ ខែ ឆ្នាំណា? (២ ᧳ ៥ ឆ្នាំម្សាញ់ ត្រីស័ក ស. ព. ២៤៨២ ត្រូវនឹងថ្ងៃទី២៤ ខែមេសា គ. ស. ១៩៤១ ។

ការហាត់សរសេរ– ចូរបន្ថែមពាក្យឲ្យពេញត្រឹមត្រូវនៅ-កន្លែងចន្លោះ

នៅក្រុងភ្នំពេញ ចំទន្លេបួនមុខមានព្រះ.......ព្រះករុណាជាម្ចាស់ជីវិតលើត្បូងយ៉ាងរុងរឿង ។ ក្នុងព្រះបរមរាជវាំង មានព្រះរាជមន្ទីរជាច្រើនគឺ..................ខាងក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមានព្រះ..........ដំកល់.........ប្រាំបួនជាន់ ។ នៅមុខព្រះបរមរាជវាំងខាងមាត់ទន្លេមាន.....................សំរាប់ព្រះករុណាស្ដេចយាងទៅគង់ក្នុងព្រះរាជពិធី-បុណ្យអុំទូក (សំពះព្រះខែ) តាមទំនៀមទំលាប់ ។

## បង្រៀនមើល

ជីក្រុងនិងស្រុកស្រែ

(សៀវភៅវិជ្ជាខេមរភាសា សាគារិកដ្ឋាន ទំព័រ ៦៧)

ហាត់ភាសា.- សំរិតនៅឯណា? ត្រូវជាអ្វីនឹងគិម? គិមនៅឯណា? សំរិតសរសេរសំបុត្រទៅគិមថាដូចម្តេច? អ្នកដែលឃើញពន្លឺភ្លើងអគ្គិសនីឬទេ? ពន្លឺនោះយ៉ាងណា? គិមសរសេរសំបុត្រតបទៅសំរិតវិញថាយ៉ាងណា? គិមថានឹងនាំសំរិតទៅបេះផ្លែឈើអ្វីខ្លះ? នឹងដើរទៅលេងនៅទីណា ? ព្រោះអ្វី? អ្នកចូលចិត្តនៅទីក្រុងឬស្រុកស្រែ ? ហេតុអ្វី? ។

ការហាត់សរសេរ.- សូមធ្វើតាមការហាត់ក្នុងមេរៀននេះ នៅទំព័រ ៦៤ ។

## សរសេរតាមសូត្រ

### ព្រះបរមរាជវាំង

នៅក្រុងភ្នំពេញ មានព្រះបរមរាជវាំងដ៏ធំថ្កើងរុងរឿងមានកំពែងឥដ្ឋខ្ពស់ព្រោសពណ៌ជុំវិញ ។ ខ្លោងទ្វារខាងកើតបែរបំពៅទៅទន្លេបួនមុខ ។ ក្នុងព្រះបរមរាជវាំងមានព្រះទីនាំងទេវាវិនិច្ឆ័យធំទូលាយដ៏ស្ញប់ស្ញែង ដំបូលឡើងជារួតមានរូបគ្រុឌទ្រ ខាងចុងកំពូលមានព្រះភក្ត្រព្រះព្រហ្មញញឹមទៅរកទិសទាំងបួន ហើយមានកំពូលត្រីសូលខ្ពស់ស្រួច ។ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ មានព្រះបល្ល័ង្ករាជ្យដ៏មានស្វេតច្ឆត្រប្រាំបួន

ជាន់គ្រប់ពីលើ ៗ នៅកំពែងខាងក្នុងមានព្រះមហាប្រាសាទខេមរិន្ទ ដែលជាដំណាក់សម្រាប់ព្រះករុណាជាម្ចាស់លើត្បូងគង់នៅ ៗ

សរសេរពាក្យពិបាក ៈ— បរមរាជវាំង – ឥដ្ឋ – ព័ទ្ធ – ចតុមុខ - ព្រះកន្ត្រព្រះព្រហ្ម – ត្រីសូល៍ – បល្លង្ក – ស្វេតច្ឆត្រ - ស្ប់ស្បែង

## អក្សរផ្ចង់

ប ប ម ហ បិ

( សូមធ្វើដូចអាទិត្យមុន )

## តែងសេចក្ដី

ចូរអ្នកសរសេរសំបុត្រមួយច្បាប់ផ្ញើទៅមិត្តសំឡាញ់អ្នកដែលនៅស្រុកស្រែ និយាយអំពីសេចក្ដីសប្បាយគ្រប់យ៉ាងនៅទីក្រុង ៗ

សេចក្ដីផ្ដើម :

សេចក្ដីរាប់រៀប .— អំពីវាំងហ្លួង – ផ្លូវថ្នល់ – ផ្សារ – មន្ទីរផ្សេងៗ ( ផ្ទះរាជការ – សាលារៀន – រោងល្បាំ ) ៗ

សេចក្ដីបញ្ចប់.– ( ញុំាងមិត្តសំឡាញ់ឲ្យចង់ចូលទៅមើលទីក្រុង ។

## បង្រៀនពាក្យ – ហាត់ភាសា

### អាទិត្យទី៣.– ទីក្រុង (ត)

នាម.– ហាងទំនិញ ពាណិជ (អ្នកលក់ដូរអ្នកជំនួញឈ្មួញ) អម្ពរពស្ត្រ (សំពត់) គន្ធពាណិជ (អ្នកជំនួញទឹកអប់) ពាណិជ្ជកម្ម (ការប្រកអំពើលក់ដូរ, របស់លក់ដូរ) ពាណិជ្ជការ (អ្នកធ្វើជំនួញ) ក្រសួងពាណិជ្ជការ (ក្រសួងត្រួតត្រាលើពួកអ្នកធ្វើជំនួញ) អាហារ = ចំណី យាន = ទោចក្រ ត្រីចក្រ រថ រទេះ រថយន្ត កង់អគ្គីឬកង់ចក្រ គោម ចង្កៀង ប្រទីប អគ្គិសនី ខ្សែលួសភ្លើង ម៉ាស៊ីនទឹក នាវា = កប៉ាល់ ទូក កាណូត ថ្ងៃ ប៊ុកចាយ ។

គុណនាម.– ចំណេញ ខាត ក្រអូប ល្អ បរិបូណ៌ ឆ្ងាញ់ ប្រសើរ ថ្លៃក រហ័ស ឈ្មួរ កកកុញ គាន់គាប់ ។

កិរិយាសព្ទ.– ទៅ មក ចេញ លក់ ទិញ តថ្លៃ ជិះ ដើរ បើក បរ ផាក់ វិល បំភ្លឺ ទាញកញ្ចែ បត់ កាច់ចង្កូត បើកក្ដោង ដឹកទំនិញ បញ្ជូន រវល់ ជួន សែង យួរ រែក ។

ការហាត់សរសេរ.— ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ

អ្នកដែលទៅហាងទំនិញឬទេ? អ្នកត្រូវការទិញវត្ថុអ្វីខ្លះ ? អ្នកជំនួញទឹកគប់ហៅថាអ្វី ? ចុះអ្នកធ្វើជំនួញឬអ្នកត្រួតត្រាលើពួកអ្នកធ្វើជំនួញហៅថាអ្វី ? យានកង់ពីរហៅថាអ្វី ? បើធ្វើដំណើរតាមផ្លូវគោកគេប្រើយានអ្វី? តាមផ្លូវទឹកគេប្រើអ្វីខ្លះ ? ។

## បង្រៀនមើល

## ចិននៅប្រទេសឥណ្ឌូចិន

(សៀវភៅខេមរភាសាអានទកដ្ឋានទំព័រ ២០)

ហាត់ភាសា = នៅប្រទេសឥណ្ឌូចិនមានជនជាតិដទៃអ្វីខ្លះ ? មានជនជាតិអ្វីច្រើនជាងគេ ? ចិនមកពីខេត្តណាខ្លះ? កូនចៅចិនដែលតាំងទីលំនៅខ្ជាប់ខ្ជួនក្នុងប្រទេសឥណ្ឌូចិនហៅថាអ្វី ? ចិនមានចិត្តយ៉ាងណាក្នុងការរកស៊ី ? ចិនដែលនៅក្នុងស្រុកខ្មែរយូរមកហើយរកស៊ីអ្វី ? ចិននៅក្រុងភ្នំពេញរកស៊ីអ្វី ? ជនជាតិណាធ្វើជំនួញ ? ការជំនួញរបស់ចិនបានចំរើនឬទេ ? ប្រាក់ចំណេញចិនយកទៅណា ? អ្នករាល់គ្នាត្រូវធ្វើដូចម្តេចដើម្បីកុំឲ្យចិនបោកបាន ? ។

# សរសេរតាមសូត្រ

## ផ្ទះលក់ទំនិញ

កាលពីថ្ងៃអាទិត្យមុននេះ ខ្ញុំជូនម្ដាយខ្ញុំទៅទិញសំពត់ព្រែនៅហាងលក់ទំនិញមួយនៅខាងលិចផ្សារថ្មី ។ នៅក្នុងហាងនោះខ្ញុំឃើញគេដាក់ទូកញ្ចក់វែងភ្ជាប់ទៅនឹងជញ្ជាំងតាំងសងខាង ជិតមាត់ទ្វារចូលមានតុមួយវែងសម្រាប់ទទួលប្រាក់ ក្នុងថ្នាក់ទូកញ្ចក់និមួយៗ មានដាក់វត្ថុច្រើនយ៉ាងដូចជាមួក ឆត្រ ស្បែកជើង ទឹកអប់ សំពត់ព្រែលាតនឹងព្រែផ្កាង មានពណ៌ផ្សេងៗ នៅមុខទូខ្ញុំឃើញមានបានគ្រប់យ៉ាង ពែង តូច ធំ នឹងឆ្នាំងស្ពាន់ ដែក ។

សរសេរពាក្យពិបាក = កញ្ចក់ ភ្ជាប់ ជញ្ជាំង ទ្វារ តុ វត្ថុ ពណ៌ ស្ពាន់ ដែក ។

# តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីផ្ទះហាងលក់ទំនិញមួយដែលអ្នកបានស្គាល់ច្បា

កង៖ តើផ្ទះនោះសង់បែបដូចម្ដេច ? ធ្វើអំពីអ្វី ? នៅក្នុងហាងនោះអ្នកឃើញមានទំនិញអ្វីខ្លះ ? គេរៀបចំលក់បែបយ៉ាងណា ? យោបល់យល់ឃើញអំពីហាងចិនលក់ទំនិញនោះ ។

អាទិត្យ ទី៤.–

សូមសាបង្រៀនតាំងពីដើមឡើងវិញ

---

## បរិច្ឆណាដ្ឋាន

### រៀនពាក្យ – ហាត់ភាសា

អាទិត្យទី១.– ការធ្វើស្រែចំការ

នាម.– នង្គ័ល, រនាស់, រទេះ, អង្គប់ស្នាប, ចប, កាំបិត, គោ; ក្របី, សេះ ។

គុណនាម.– ស្រួល, កោង, តឹង, ធូរ, ធំ, ចបចាស់, ថ្មី; គោខ្លាំង, ក្របីអត់ ។

កិរិយា.– ភ្ជួរ, រាស់, បង្រាប, បញ្ចូល, លើកដី, អូស, ទាញ, ។

ភាសា = ទីធ្លីស្រែចំការ គេប្រើប្រដាប់អ្វីខ្លះ? គេប្រើធ្វើអ្វី នង្គ័លរនាស់? រទេះ? ចប?

វិធីហាត់.— ចូរបំពេញត្រង់ចន្លោះដោយពាក្យដែលត្រូវប្រើ អ្នកស្រែចំការគ្មាន.......ប្រើការធ្វើស្រែចំការពុំបានឡើយ ព្រោះទីធ្លីប្រើ ឬត្រូវឡើងដីស្រែធំល្វឹងល្វើយគេ.....ដីដោយនង្គ័ល ។ ដីច្បារដំណាំជួយ ដោយ......បាន ។ ហេតុនេះបានជាគេពុំដែលឃើញអ្នកថែសួនច្បារមាន នង្គ័លឡើយ ។

អាទិត្យទី ៦.- ការធ្វើស្រែចំការ (ត)

នាម - រនាស់ដៃ, ចបកាប់, ចបចូក, យាម; ផ្សៀង, ផាល, ដង, នឹម, មេរនាស់, ឈ្នាញ, កង់, ទូក, បន្ទោល, ប្រែក, ត្បួ, ជ្រោង, ស្នាប, គន្ទង, អាចម៍បំណះ, បង្ហួរ, ស្រែ, ថ្នាល, ចំការ, សំណាប, សំទូង, ជួរ, រង, រណ្ដៅ, ក្ទឹ, ទំនប់, រង្វះ, ប្រឡាយ ។

គុណនាម.— ជីជូរ ហាប់ ល្បាយ រឹង ជ្រាយ ដនង យាម គោង ប្រែកត្រង់ ប្រែកង គន្ទង ជ្រៅ អាចម៍បំណះរដិបរដុប ស្រែពបស្មើ សំណាបស្រស់ ខៀវ ខ្ចី ចាស់ សំទូងញឹក រង្វើល រងវែង ។

កិរិយា.— គោស ជីក ជំរះ ស្ទូង សាប ព្រោះ ឬកដាំ លើកភ្លឺ

ប្រែដី (ភ្ជួរទីពីរ) គាស់ បញ្ចូលទឹក ស្ដារទឹក បើករង្វះ ទប់រង្វះ ថែទាំ រក្សា ដាក់ជី សំអាតដំណាំ បោចស្មៅ បេះស្លឹក ក្រៀវ (ក្ដិបត្រួយចេញ)

## អាទិត្យទី៣.– ការធ្វើចំការ (ត)

នាម.– ដំណាំ ស្រូវប្រាំង ស្រូវវស្សា ស្រូវធ្ងន់ ស្រូវស្រាល ស្រូវកន្ទុះ (ស្រូវបីខែ) ស្រូវដំណើប ស្រូវខ្សាយ ពោត សណ្ដែកបាយ សណ្ដែកសៀង សណ្ដែកដី ល្ង ត្រុម ថ្នាំ កប្បាស ឪឡឹក ត្រសក់ អំពៅ ត្រឡាច ល្ពៅ ននោង ត្រសក់ស្រូវ ត្រសក់ផ្អរ ។

គុណនាម.– ខៀវ លឿង ក្រហម ទុំ ខ្ចី ចាស់ ស្រគាល ក្រិន ស្រពោន ក្រៀម ស្វិត ស្រស់ ជូរ ល្វីងផ្អែម ចត់ ប្រហើរ ក្រពុល ខ្សោះ ស្រួយ សាច់ណែន ជ្រោក ជ្រាយ ។

កិរិយា.– ដាំ ព្រោះ ស្ទូង, សាប បណ្ដុះ ជ្រួយ ពូន ក្ដិបស្លឹក បេះ ដម្រង់ ផ្ដក លប់គល់ ដក ផ្សាំ ស្រោច គោះ ដម្រុះ ហាន់ ហាល ប្រមូល ចងបាច់ ដឹក ដញ្ជូន បោក បែន រៀប គរ ផ្ដុំ ពោយ បក់ អុម រែង ។

## អាទិត្យទី៤.– ការធ្វើស្រែចំការ (ត)

នាម.– ពូជ គ្រាប់ សំបក ចំបើង សំណុស ផោក ជាល ដង្រុក កញ្ជើ ប៉ាតែ ការុង បាញ់ (ថ្នាំ) សា (ដំណាំដុះលេចចេញពីគល់ដែលច្រូតកាត់ហើយ) ជ្រញ់ថ្នាំ ។

គុណនាម.–ពូជល្អ គ្រាប់ថ្មី ជង្រុកពេញ ថ្នាំខ្លាំង ថ្នាំខ្សោយៗ

កិរិយា.- ទុកពូជ ប្រលេះគ្រាប់ បកសំបក ប្រកដោក កើបរាល់ បត់ធ្វើបាញ់ ផ្អាប់ទុក ហាលសន្សើម បន្ទុំ ហាន់ ៗ

## រៀនមើល

អាទិត្យទី១ .-

១.– អំពីគ្រឿងប្រដាប់ធ្វើស្រែចំការ ( បរិវត្ត.ទំព័រ ២១ ) ពាក្យពិបាកអាននង្គ័ល ( នាង៍គល់ ) គាស់ ( គ័រស ) រាស់ ( រ័រស ) រនាស់ ( រ័នរស ) អន្ទង់ ( អនលុង ) រាប ( កុំប្រឡំនឹងរៀប )

២.– នង្គ័ល ( សៀវភៅដដែលទំព័រ ៥០ )

៣.– ក្រពី ( សៀវភៅដដែលទំព័រ ៥២ )

សព្ទពាក្យ.– ដំណើរអើត = ដើរក្បាលងើប ៗ

ចិត្តធ្ងន់ = មានអំណត់ក្នុងការធ្វើ ៗ

អាទិត្យទី ២.–

១.– សត្វស្លាបមានប្រយោជន៍ដល់អ្នកធ្វើស្រែចំការ (សៀវភៅបរិវត្ត. ទំព័រ ៥៣)

២.– សត្វពាហនៈ ( សៀវភៅដដែលទំព័រ ៧៦ )

៣.– អំពីផ្លែពោត ( សៀវភៅដដែលទំព័រ ៩៧ )

អាទិត្យទី ៣ និងទី ៤.–

១.– អំពីឬហើយនឹងគ្រាប់ញ ( សៀវភៅបរិវុឌ្ឍ. ទំព័រ ៩៨ )

២.– របរអ្នកធ្វើស្រែ (សៀវភៅដដែលទំព័រ ១៣៣)

៣.– ការកាប់ពោតនឹងប្រយោជន៍នៃពោត (វត្ថុស្វាធ្យាយន៍ បរិវុឌ្ឍ. ទំព័រ ៤៩ )

## សរសេរតាមសូត្រ

អាទិត្យទី ១.–

១.– រឿងមើលទី ១ អំពីគ្រឿងប្រដាប់ធ្វើស្រែចំការ

២.– រឿងមើលទី ២ នង្គ័ល

៣.– រឿងមើលទី ៣ គ្រប់

អាទិត្យទី ២.–

១.– ការធ្វើស្រែ(វត្ថុស្វាធ្យាយន៍ បរិវុឌ្ឍ. ទំព័ ៤៤ ដល់រួចជាស្រេច)

២.– របៀបធ្វើអង្ករ (សៀវភៅដដែលទំព័រ ៤៦ ដល់ដាក់ជង្រុក)

៣.– របៀបធ្វើអង្ករ ( ត )

អាទិត្យទី ៣ និងទី ៤.–

១ - ២ អំពីវ ហើយនិងក្រវាញ ។

៣ - ៤ ការរបរអ្នកធ្វើស្រែ ។

---

កុមារដ្ឋាន

| រៀនពាក្យ - ហាត់ភាសា |
|---|

អាទិត្យទី១– សំលៀកបំពាក់

សំពត់ស្លៀក, ខោ, អាវ, សារុង, អាវកុត, អាវទ្រនាប់ ។ សំពត់ថ្មី, ខោទូលាយ, អាវស្រុង, សារុងស្វយ, អាវករង, អាវបង្អៀត, ស្លៀកសំពត់, ចងក្បិន, ពាក់អាវ, បិទអាវ, ដោះអាវ, ផ្លាស់សំពត់

ភាសា.– ខ្ញុំស្លៀកអ្វី ? ពាក់អ្វី ? ខ្ញុំប្រុសនិងស្រី ស្លៀក-ពាក់ដូចគ្នាឬទេ ? ក្មេងប្រុសស្លៀកពាក់ដូចម្តេច ? ។

អាទិត្យទី២.– សំលៀកបំពាក់ (ត)

សំពត់សូត្រ អំបោះ សម្បកឈើ ព្រែឡាញ់ កាមញី តួន (ព្រែធ្វើនិងសរសៃរុក្ខជាតិ) សំពត់ផាមួង ហូល ល្បើក អន្លូញ សំ

ពត់ប៉ាកំង (សំពត់អំបោះក្រឡាញឹក) ផាហំ ក្រមាស៊ី (ក្រមាពណ៌) ក្រមាផ្កា ខៀវ, សំពត់សំឡុយ ។

សំពត់ទន់ រលើប គគ្រាត ម៉ដ្ឋ គ្រើម ក្រហម ខៀវ ខ្មៅ ស លឿង ស្វាយ បៃតង ជាំព្រីងទុំ ជម្ពូ ស្រស់ ស្រអាប់ ដាច់ ផុយ-ធន់ ថ្លៃ ថោក ។

បិទផ្ទាំង រ័ត្ន រ័ណ្ឌ គ្រប ដណ្ដប់ បង់ ពានា បង ពុង គ្រលុំ ទទូរ ប្រើប្រាស តែង ។

## អាទិត្យទី ៣.– សំលៀកបំពាក់ (ត)

សំលៀកលោកសង្ឃ សំលៀកយួន ចិន ខ្មែរ ចីពរ សង្ឃាដី ស្បង់ ហង្សក វត្តពន្ធ សំពត់ឆ្នូត (សាដក) ។ ឆ្នូតក្បាល អាវបំពង់វែង អាវខ្លី ខោស្នាប់ភ្លៅ ។ ទូលាយ បង្អៀត តឹង ធូរ ។ គ្រង ឃ្លុំ ស្លៀក បង់វត្តពន្ធ ជ្រលក់ លាង ដុស ពាក់ ផ្លាស់ ព្រាប់ ដណ្ដប់ រុំ ក្រាល បត់ អង្គាញ់ ។

## អាទិត្យទី ៤.– សំលៀកបំពាក់បារាំង

អាវបើកក អាវស៊ីមិស អាវពិសាមា អាវយឺត ហ្វូកុល ក្រវ៉ាត់ក អាវកេ៉ប ខោវែង ខោខ្លី ស្រោមជើងវែង ស្រោមជើងខ្លី ស្បែក-

ដើរក្រោប ស្បែកជើងសក្រែក ។

បង្អៀត ខ្ញុំ ល្មម រឹង ស្អាតលាន់ ផុស ក្បោក អ៊ុត ។

## រៀនមើល

អានិត្យទី១និងទី២.— ផ្ញើដើរ (សៀវភៅទំព័រ ៦១)

ជម្ពូទាន អក្សរ (រ) មានសម្លេងពីរគឺ រ និង ៉ (មូសិកទន្តលើ) (រ)ជា ៉ ។ ឯជើង(រ) បើគេវាក់អក្សរអ ឃោសៈជា ( ៉) ដាំងអស់ ក្រ ប្រ ក្រ បើគេវាក់អក្សរឃោសៈជា(រ) ដាំងអស់ គ្រ ជ្រ ទ្រ ព្រ មិនបាច់មូសិកទន្តឡើយ ។

(មេរៀនលេខ១២៤) អក្សរដែលមានសម្លេងតែមួយហៅថាអក្សរឯកសព្ទ= ក ខ គ ឃ ច ឆ ជ ឈ ដ ឋ ឌ ឍ ត ថ ទ ធ ផ ព ភ ឡ ។ អក្សរដែលមានសម្លេងពីរហៅថាអក្សរទ្វិសព្ទ=ង ញ ណ ន ប ម យ រ ល វ ស ហ អ ។ ឯអក្សរ (ប) មានសម្លេងបី ទើបគេហៅថាអក្សរត្រៃសព្ទ ។ អក្សរទ្វិសព្ទនិងត្រៃសព្ទផ្លាស់សម្លេង-ដោយវណ្ណយុត្តិមូសិកទន្ត ( ៉) ឬត្រីសព្ទ ( ៊) កាលណាអក្សរនោះ-នៅជាដើមបទ បើនៅចុងបទវិញ ផ្លាស់សម្លេងទៅតាមអក្សរដើមបទ

មិនបាច់វណ្ណយុត្តិឡើយ– ន៉ានក្ងាន ញ៉ាំ កញ្ញម...... ។ ជើងអក្សរទ្វិសព្ទផ្លាស់សម្លេងទៅតាមតួលើ បើតួលើជាឃោសៈ ជើងដែលទៅផ្ញើក៏ជាឃោសៈ បើតួលើជាអឃោសៈ ជើងដែលទៅផ្ញើក៏ជាអឃោសៈ= ក្ង ច្ង គ្ឃ ខ្ឃ ឃ្ង ទ្ង ...... ។ ឯជើងអក្សរឯកសព្ទមិនផ្លាស់សម្លេងឡើយ= ស្គ ស្ក ខ្ន ខ្ព ខ្ឈ (មើលមេរៀន២៥,២៦,២៧ )

សេចក្តីចំណាំ= អក្សរ ណ ន ល ផ្លាស់សម្លេងមិនបាច់វណ្ណ-យុត្តិ ( ៉ ) ឬ ( ៊ ) ។

អាទិត្យទី៣ ថ្ងៃទី ៤.- នឹងបង្រៀនព្យញ្ជនៈ ផ្សំឬផ្ញើជើង សុំមើលផ្សន្ទានខាងលើ ហើយនឹងមេរៀនក្នុងសៀវភៅពីលេខ ២៥, ២៦, ២៧

---

## តែងសេចក្តី

### សម្រាប់

### ប្រឋមភូមិបំពេញវិជ្ជា

កម្មវិធីសំរាប់ខែ– ពិព័ណ៌នាអំពីមនុស្ស អំពីវិការដ្ឋាននឹងអំពីទីកន្លែង ។

១– ពិពណ៌នាអំពីមនុស្ស

សេចក្ដីលំនាំ - ដើម្បីធ្វើពិពណ៌នាអំពីមនុស្ស ដំបូងគេធ្វើពិពណ៌នាអំពីរូបរាង បន្ទាប់មក ពីខាងផ្លូវចិត្តនៃមនុស្សនោះ ។

នៅក្នុងការធ្វើពិពណ៌នាអំពីរូបរាង គេកត់លក្ខណៈណាដែលលេចផុសឡើងជាងគេ ។ រួចទើបគេអធិប្បាយអំពីទឹកមុខ សំលៀកបំពាក់និងអាកប្បកិរិយានៃជននោះ ។

នៅក្នុងការធ្វើពិពណ៌នាខាងផ្លូវចិត្ត គេដំណាលអំពីគុណសម្បត្តិខាងប្រាជ្ញានិងខាងទឹកចិត្តនៃបុគ្គលនោះ ( ចរិត – ទម្លាប់ – គំនិតមារយាទ )

សេចក្ដីតែង– ចូរអ្នកធ្វើពិពណ៌នាអំពីពួកអ្នកអារឈើហុប ។

គោលសេចក្ដី

១– កន្លែងដែលអ្នកបានឃើញអ្នកអារឈើធ្វើការ ។

២– ពិពណ៌នាអំពីទឹកមុខ សំលៀកបំពាក់ ។

៣ – កិច្ចការរបស់អ្នកអារឈើ ៖

ក– គេដាក់ឈើហុបដូចម្ដេចដើម្បីនឹងអារឲ្យត្រង់ (ដឹកបន្ទាត់) ។

ខ– គេឈររបៀបណាដើម្បីធ្វើការ ។

គ– រណាចុះឡើងៗហើយបញ្ចេញសូររបៀបណា ? គេលាបមុខរណានឹងអ្វីដើម្បីកុំឲ្យស្អិត ?

ឃ- សេចក្ដីប្រឹងប្រែងជាទៀងហើយ យ៉ាងលំបាកនៃដៃជើង ទ្រូង នឹងចង្កេះ ។

ង- សេចក្ដីបញ្ចប់៖ ផលប្រយោជន៍ ក្នុងបច្ចុប្បន្នសម័យនេះ គេកាន់តែប្រើម៉ាស៊ីនអារឈើជួសកម្លាំងមនុស្សច្រើនណាស់ហើយ ។

២- ពិពណ៌នាអំពីវិការដ្ឋាន

សេចក្ដីលំនាំ- វិការដ្ឋានកើតឡើងដោយមនុស្សច្រើនរូបបំពេញអំពើមួយក្នុងកន្លែងណាមួយនឹងក្នុងកំឡុងពេលមួយមានកំណត់ ។ ដើម្បីធ្វើពិពណ៌នាអំពីវិការដ្ឋាន ដំបូងគេរាប់រៀបអំពីក្របខណ្ឌ (ទីកន្លែង នឹងពេលវេលាដែលវិការដ្ឋាននោះកើត) រួចអំពីមនុស្សសំខាន់ ៗ ក្នុងវិការដ្ឋាននោះដោយអធិប្បាយអំពីអំពើនៃជនទាំងនោះ ។

គេបញ្ចប់ការតែងដោយបញ្ចេញការចាប់អារម្មណ៍ ឬយោបល់របស់គេ ។

សេចក្ដីតែង នៅពេលព្រលប់ ពួកក្រុមញាតិអ្នកមកប្រជុំគ្នានៅជុំវិញចង្កៀង ចូរអ្នកធ្វើពិពណ៌នាអំពីវិការដ្ឋាននេះ ។

គោលសេចក្ដី

១- ក្របខណ្ឌ៖ កន្លែង វេលា បរិយាកាសខាងក្រៅផ្ទះ ។

២- ចង្កៀងមួយបំភ្លឺ វិការដ្ឋាននៃពួកក្រុមញាតិ ។

៣- ពួកក្រុមញាតិម្នាក់ៗ: អាកប្បកិរិយា កិច្ចការ ។

៤- ការចាប់អារម្មណ៍ៈ សេចក្តីគោរពយក្នុងក្រុមញាតិ គួរអាសូរដល់ក្មេងកំព្រា ។

៣- ពិពណ៌នាអំពីទីកន្លែង

សេចក្តីតែង- ចូរអ្នកធ្វើពិពណ៌នាអំពីភូមិកំណើតអ្នក ។

គោលសេចក្តី

១- ទីកន្លែងនិងទិដ្ឋភាពទាំងមូលនៃភូមិអ្នក (មើលពីចម្ងាយឃើញដូចព្រៃមានតែដំបូលព្រះវិហារប្រក់ស្លឹកក្រហមផុសចេញពីចុងរុក្ខជាតិនានា) ។

២- នៅក្នុងបរិវេណភូមិៈ ផ្លូវដើរ ផ្លូវរទេះបត់បែនដូចពស់លូនកាត់វាលស្រែទៅកាន់ថ្នល់បុកគ្រួស ។ គេហដ្ឋានជាច្រើនប្រក់ស្លឹកសង់កប់នៅកណ្ដាលចំការរុក្ខជាតិស្រុក ឧត្ដុប្បករណ៍ដាក់ពាយមាយពេញក្រោមផ្ទះជាមួយនឹងត្បាល់កិន ត្បាល់បុក ។ អ្នកខ្លះចងឈើព័ទ្ធក្រោមផ្ទះធ្វើជាក្រោលសត្វ ។ សាលាឃុំ សាលារៀនសង់នៅត្រង់ណា? ជាទីស្អាតឬទេ? នៅជុំវិញភូមិមានអ្វី? (វាលស្រែដែលមានទិដ្ឋភាពប្រែប្រួលតាមរដូវ) ។

៣- ជីវភាពនៃភូមិៈ អ្នកស្រុកដើរក្រោយគោក្របី លីកាំបិត

ចេញទៅប្រកបការងារពីព្រលឹម ស្រីៗនិយាយឆ្លងឆ្លើយគ្នាពីផ្ទះមួយទៅផ្ទះមួយ សូរត្បាល់ជាន់អង្ករគ្រុំៗ ត្បាល់កិនស្រូវរ៉ូវៗ សំរែកក្មេងយំលាយនឹងសំឡេងម្តាយបំពេរ សំឡេងមាន់ខ្តតប្រណាំងនឹងឆ្កែព្រុសៗ

៤– សេចក្តីបញ្ចប់ ៖ ភូមិកំណើតខ្ញុំបាទពិតមែនតែគ្មានគេហដ្ឋានធំ គ្មានផ្លូវក្រាលកៅស៊ូបំភ្លឺដោយចង្កៀងអគ្គិសនីនៅពេលយប់ តែខ្ញុំបាទមានចិត្តស្នេហាភូមិនោះយ៉ាងខ្លាំង ព្រោះជាទីដែលខ្ញុំបាទបានកើតកប់សុខទុក្ខឈាមទឹងជាទីដែលមាតាបិតាដូនជីតាព្រមទាំងពួកបងប្អូនខ្ញុំបាទកើតរស់នៅដោយរីករាយតៗគ្នាជាយូរលង់ណាស់មកហើយ ។

## ផ្ទាក់អាចិតដ្ឋាន

## តែងសេចក្តីទី ១

ចូរតែងសេចក្តីអធិប្បាយអំពីជាងកំបោរ តាមពាក្យចោទខាងក្រោមនេះ ៖

នៅភូមិអ្នកមានជាងកំបោរឬទេ? ជាងនោះឈ្មោះអ្វី? គាត់មានប្រដាប់អ្វីខ្លះសម្រាប់ធ្វើការ? ពេលដែលគាត់ធ្វើការអ្នកបានឃើញគាត់ធ្វើដូចម្តេចខ្លះ?

## គំរូតែងសេចក្ដី

នៅភូមិខ្ញុំមានជាងកំបោរម្នាក់ ។ ជាងនោះឈ្មោះនន់ ។ គាត់មានប្រដាប់សម្រាប់ធ្វើការគឺ ៖ ប៉ែល, ថាំងឈើ, ឈើគ្នាស, ក្ដារទ្របាយអរ, ស្នាបព្រាដែកនិងកែវស្ទង់ ។ ពេលដែលគាត់ធ្វើការខ្ញុំបានឃើញគាត់យកខ្សាច់និងកំបោរចាក់លាយគ្នា ហើយយកទឹកមកចាក់ថែមទៀតដើម្បីឲ្យខ្សាច់និងកំបោរលាយចូលគ្នាជាបាយអ រួចស្រេចទើបគាត់ចូកនឹងប៉ែលដាក់ទៅក្នុងថាំងឈើតូច យួរយកទៅកន្លែងធ្វើការហើយយកស្នាបព្រាដែកចូកដាក់ទៅលើឥដ្ឋហើយដាក់ឥដ្ឋមួយភ្ជាប់ពីលើធ្វើដូច្នេះត ៗ គ្នាកើតបានជាជញ្ជាំងផ្ទះមួយ ។

## តែងសេចក្ដីទី ២

ចូរតែងសេចក្ដីអធិប្បាយអំពីជាងដែកតាមពាក្យចោទខាងក្រោមនេះ ។

នៅភូមិអ្នកមានជាងដែកឬទេ ? ជាងនោះឈ្មោះអ្វី ? គាត់សង់រោងនៅខាងណាភូមិអ្នក ? នៅក្នុងរោងនោះមានប្រដាប់អ្វីខ្លះសម្រាប់ជាងធ្វើការ ? ជាងដែកមានប្រយោជន៍នឹងយើងឬទេ ? ពីព្រោះអ្វី ?

## តែងសេចក្ដីទី ៣

### អំពីជាងឈើ

សូមគ្រូរៀបចំរឿងតែងនេះ

## ថ្នាក់បរិវឌ្ឍណាដ្ឋាន

### តែងសេចក្ដីទី ១

ចូរតែងសេចក្ដីអធិប្បាយអំពីក្រុមញាតិអ្នក តាមពាក្យចោទខាងក្រោមនេះ ? ក្នុងក្រុមញាតិអ្នកមានមនុស្សប៉ុន្មាននាក់? មនុស្សទាំងនោះគឺអ្នកណាខ្លះ? ឪពុកម្ដាយអ្នកចាស់ហើយឬនៅក្មេងទេ? គាត់មានកូនប៉ុន្មាននាក់ ? កូនប្រុសប៉ុន្មាននាក់ ? កូនស្រីប៉ុន្មាននាក់ ? អ្នកស្រឡាញ់ឪពុកម្ដាយអ្នកឬទេ ? ពីព្រោះអ្វី ?

### គំរូតែងសេចក្ដី

ក្នុងក្រុមញាតិខ្ញុំមានមនុស្សប្រាំនាក់ ។ មនុស្សទាំងនោះគឺ ៖ ឪពុកខ្ញុំ ម្ដាយខ្ញុំ, បងខ្ញុំ, ប្អូនខ្ញុំ, និងខ្ញុំ ។ ឪពុកម្ដាយខ្ញុំចាស់ហើយ ។ គាត់មានកូនបីនាក់ ។ កូនប្រុសម្នាក់, កូនស្រីពីរនាក់ ។ ខ្ញុំស្រឡាញ់ឪពុកម្ដាយខ្ញុំណាស់ ។ ពីព្រោះគាត់បង្កើតខ្ញុំ និងបីបាច់ថែរក្សាខ្ញុំផង

### តែងសេចក្ដីទី ២

ចូរអធិប្បាយអំពីបងប្អូនទីងក្ឃយរបស់ឪពុកម្ដាយអ្នក តាមពាក្យចោទខាងក្រោមនេះ ។

ឪពុកម្ដាយអ្នកមានបងប្អូនបង្កើតស្រីប្រុសឬទេ ? បងប្រុសឬបងស្រី

ឪពុកម្ដាយអ្នកត្រូវជាអ្វីនឹងអ្នក? ប្អូនប្រុសប្អូនស្រីឪពុកម្ដាយអ្នកត្រូវជាអ្វីនឹងអ្នក? កូនឪពុកធំម្ដាយធំកូនមាមីងអ្នកត្រូវជាអ្វីនឹងអ្នក?

## តែងសេចក្ដីទី ៣

ចូរអធិប្បាយអំពីក្រុមញាតិអ្នកធ្វើបុណ្យនិមន្តលោកឆាន់ តាមពាក្យចោទខាងក្រោមនេះ ៗ ក្រុមញាតិអ្នកដែលធ្វើបុណ្យនិមន្តលោកឆាន់ឬទេ? មុនធ្វើបុណ្យអ្នកឃើញគេរៀបចំផ្ទះដូចម្ដេចខ្លះ? ដល់យប់គេបាននិមន្តលោកមកសូត្រមន្តឬទេ? នៅពេលលោកសូត្រមន្តមានមនុស្សមកស្ដាប់ច្រើនឬតិច? លុះព្រឹកឡើងគេធ្វើអ្វីប្រគេនលោកឆាន់? អ្នកត្រេកអរនឹងក្រុមញាតិអ្នកធ្វើបុណ្យឬទេ? ពីព្រោះអ្វី?

---

## អាទិកដ្ឋាន

### នព្វន្ធ

អាទិត្យទី ១.– លេខគុណ

សូមសាបច្រៀនលេខគុណ ៦-៧-៨-៩ នឹង ១០ ឲ្យសិស្សសូត្រមេលេខគុណដែលបានដាក់ឲ្យរៀនចាំងប៉ុន្មាន ឲ្យសូត្រហើយសួរ

ចោទផង ៗ ឧបមា: ដូចជាត្រូវថាប៉ុន្មាន ៧ បីដង? ៦ បួនដង? ៩ ប្រាំពីរដង? ៨ ពីរដង? ៗ ល ៗ សួរដូច្នេះហើយ ត្រូវសួរជាចំណោទវិញ ៗ

ឧបមា: ខ្ញុំទិញសៀវភៅ ៨ ថ្លៃមួយ ៣ រៀល តើខ្ញុំត្រូវឲ្យប្រាក់ទៅគេប៉ុន្មាន?

— លេខគុណ ៥ ទឹង ៦ (មើលសៀវភៅនព្វន្ដទំព័រ ៣៣-៣៤)

= លេខគុណ ៧ ទឹង ៩ (មើលសៀវភៅទំព័រ ៤៤.៤៥)

វិធីហាត់មាត់ឧទេធធ៍ហាត់សរសេរ.-

សូមជ្រើសរើសរកវិធីចាំងប៉ុន្មាន ដែលមានក្នុងសៀវភៅនៅទំព័រដែលបង្ហាញខាងលើស្រាប់ ដាក់ឲ្យសិស្សធ្វើផងចុះ ៗ

អាទិត្យទី ២.- លេខគុណ-ចែកទឹង ២-៤ ២០-៤០ ទឹងគុណឬចែកលេខធាប់ សូមធ្វើដូចរបៀបនេះ គុណទឹង ២. ២៦×២ គឺ ២៦+២៦ = ៥២

ចែកាធឹជ ២.- ទឹងចែកចំនួនទីមួយទឹង ២ គេត្រូវយកពាក់កណ្ដាលចំនួននោះ ដូចជា ៥០:២ គឺពាក់កណ្ដាល ៥០ មាន ២៥ ៗ

ចែកាធឹជ ៤ ទឹងចែកចំនួនទិមួយ ១ ទឹង ៤ គេត្រូវយកពាក់កណ្ដាលចំនួននោះរួចគេយកពាក់កណ្ដាលចំនួនដែលគេឃើញនោះទៀត គឺ ៦០:៤ = ពាក់កណ្ដាល ៦០ មាន ៣០ ៗ ពាក់កណ្ដាល ៣០ មាន ១៥ គេឃើញ: ៦០: ៤ = ១៥

គុណនឹង ២០-៤០ នឹងគុណចំនួនណាមួយៗ នឹង ២០ ឬ ៤០ គេត្រូវគុណនឹង ២ ឬនឹង ៤ រួចគេបន្ថែមសូន្យមួយពីខាងស្តាំចំនួនដែលឃើញនោះ ។

ឧបមា: ៣៦×២០ គឺ ៣៦×២ = ៧២ ថែមសូន្យ ១ ពីខាងស្តាំ ត្រូវជា ៧២០ ។

២៥×៤០ = ២៥×៤ = ១០០ ថែមសូន្យ ១ ពីខាងស្តាំ ត្រូវជា ១០០០

ចែកនឹង ២០-៤០ នឹងចែកចំនួនណាមួយៗនឹង ២០ ឬ ៤០ គេត្រូវចែកចំនួននោះនឹង ១០ ទើបគេយកពាក់កណ្តាលចំនួនដែលឃើញនោះ ។

ឧបមា: ៦០:២០ គឺ ៦០:១០ = ៦ ពាក់កណ្តាល ៦ គឺ ៣ ។

៦០: ២០ = ៣ ។

៨០:៤០ គឺ ៨០:១០ = ៨ ។ ភាគបួននៃ ៨ គឺ ២: ៨០:៤០=២

គឺគេយកភាគបួននៃចំនួនដែលឃើញពីការចែក ៨០:១០ ។

វិធីហាត់នឹងក្តារខៀន ត្រូវជាប៉ុន្មាន

៦០, ២៨, ៣២, ៥៨ គុណនឹង ២ ។

២៥, ៧៥, ៥០, ៣៥ គុណនឹង ៤ ។

៣០, ៧៥០, ៦៤២ គុណនឹង ២០ ។

១៦០, ២៤៨, ៣៣៦, ៧៥២ គុណនឹង ៤០ ។

ត្រូវជាប៉ុន្មាន? ៣០, ៦៤, ១២០, ២៣៦, ចែកនឹង ២ ។

– ៣៦, ៨៤, ១២៤, ៨៣៦, ចែកនឹង ៤ ។

– ៦០, ១៤០, ២៦០, ៨២០, ចែកនឹង ២០ ។

– ៨០, ១២០, ៣៦០, ៩២០, ចែកនឹង ៤០ ។

វិធីហាត់សរសេរ.– សូមរកចំណោទដាក់ឲ្យសិស្សធ្វើផងចុះ ។

អាទិត្យទី៣.– លេខគុណនិងចែក (ត)

គុណ ឬ ចែកនឹង ៥-២៥

គុណនឹង៥.– នឹងគុណចំនួនអ្វីនឹង ៥ គេត្រូវគុណចំនួននោះ នឹង ១០ ទើបគេយកពាក់កណ្តាលចំនួនដែលគេឃើញនោះ គឺ:

២៥×៥ = ២៥×១០ = ២៥០ ។ ពាក់កណ្តាល ២៥០ គឺ ១២៥ ។

ចែកនឹង ៥.– នឹងចែកចំនួនមួយនឹង ៥ គេចែកនឹង ១០ ទើបគេយកចំនួនដែលគេឃើញ ទៅគុណនឹង ២

ឧបមា: ២៥:៥ = ២៥:១០ = ២,៥០×២ = ៥

គុណនឹង ២៥.– នឹងគុណចំនួនអ្វីមួយនឹង ២៥ គេគុណនឹង- ១០០ ទើបយកភាគបួនចំនួនដែលគេឃើញនោះគឺ:

២៤×២៥ = ២៤×១០០= ២៤០០ ភាគបួន ២៤០០គឺ ៦០០ ។

ចែកនឹង ២៥.- នឹងចែកចំនួនណាមួយនឹង ២៥ គេគុណនឹង ៤ រួចគេចែកនឹង ១០០ ។

ឧបមា: ៤០០:២៥ = ៤០០×៤ = ១៦០០: ១០០ = ១៦ ។

---

អាទិតដ្ឋាន

រង្វាស់រងាស់

អាទិត្យទី១.- អំពីហិតូម៉ែត្រ

យើងបានដឹងទាំងអស់គ្នាមករួចហើយ ថារង្វាស់ ប្រវែង ១០ម៉ែត្រ គេឲ្យឈ្មោះថា ១ ដេកាម៉ែត្រ ប៉ុន្តែឥឡូវនេះមានរង្វាស់មួយទៀតវែង-ជាង រង្វាស់ដេកាម៉ែត្រ ១០ ដងទៀត រង្វាស់នេះគឺ ឈ្មោះហិតូម៉ែត្រ រង្វាស់នេះ ពុំមែនជារង្វាស់ដែលមានរូបជាក់ស្តែង ដូចជារង្វាស់ម៉ែត្រនិង ដេកាម៉ែត្រនោះទេ គឺគ្រាន់តែមានឈ្មោះ សំគាល់ថា ជារង្វាស់មានប្រវែង ១០០ ម៉ែត្រប៉ុណ្ណឹង ពីព្រោះគេមិនហៅថា ១០០ ម៉ែត្រ ២០០ម៉ែត្រ ៣០០ម៉ែត្រទេ ។ គេហៅថា ១ ហិតូម៉ែត្រ ២ ហិតូម៉ែត្រ ៣ ហិតូ-ម៉ែត្រ ។ គេសរសេរកាត់យ៉ាងដូច្នេះ ហម ។ ឧបមាថា: ៧ហិតូ-ម៉ែត្រ= ៧ ហម ។ ៣ ហិតូម៉ែត្រ= ៣ ហម ។

$៥៧៦^{\text{ម}} = ៥០០^{\text{ម}} + ៧០^{\text{ម}} + ៦^{\text{ម}} = ៥^{\text{ហម}} + ៧^{\text{ដាម}} + ៦^{\text{ម}}$

$៣៦៤^{\text{ម}} = ៣០០^{\text{ម}} + ៦០ + ៤^{\text{ម}} = ៣^{\text{ហម}} + ៦^{\text{ដាម}} + ៤^{\text{ម}}$

ហាត់គិតមាត់ទទេ– រង្វាស់ ១០ ម៉ែត្រ គេឲ្យឈ្មោះថាអ្វី ? រង្វាស់ប្រវែង ១០ ដេកាម៉ែត្រឈ្មោះអ្វី ? រង្វាស់ហិកតូម៉ែត្រគេកាន់នៅដៃវាស់បានដែរឬទេ ? ហិកតូម៉ែត្រគេប្រើសំរាប់ប្រើវាស់អ្វី ? ក្នុងមួយហិកតូម៉ែត្រមានប៉ុន្មានដេកាម៉ែត្រ ? កាលណាគេយកម៉ែត្រជាប្រធានគេត្រូវដាក់ហិកតូម៉ែត្រ នៅខ្ទង់ណាឬជួរណា ? ហេតុអ្វីបានជាគេត្រូវដាក់ម៉ែត្រនៅខ្ទង់រាយឬជួរទី១ ? គេត្រូវដាក់ដេកាម៉ែត្រនៅខ្ទង់ណាឬជួរណា ? ហេតុអ្វីបានជាគេដាក់ត្រង់ខ្ទង់ឬជួរនោះ ?

ហាត់គិតលើក្ដារខៀន– ១ ត្រូវជាប៉ុន្មានហិកតូម៉ែត្រ ប៉ុន្មានដេកាម៉ែត្រ ? ប៉ុន្មានម៉ែត្រ ? ក្នុងចំនួន $៩២៥^{\text{ម}}$ ។ $៦៧០^{\text{ដាម}}$ ។ $២១^{\text{ហ}}$ $០២^{\text{ម}}$ ។ $៩២^{\text{ហម}}$ ៦០ ។ $៤៨^{\text{ម}}$ ។ $២០៦^{\text{ដាម}}$ ៩ ។

វិធីហាត់សរសេរ.–

១.) ចូរធ្វើលេខនៅខាងក្រោមនេះ

$៧^{\text{ហម}}\ ៥^{\text{ដាម}} \times ៣^{\text{ដាម}}\ ៦^{\text{ម}}$ = ....... ម ។

$៤៣៧^{\text{ម}} \times ៣^{\text{ហម}}\ ៤^{\text{ម}}$ = ...... ហម ។

$៦៨៧^{\text{ម}} - ៤^{\text{ហម}}\ ១^{\text{ដាម}}\ ៤^{\text{ម}}$ = .... ។

២.) ១) ខ្សែលួសមួយបន្លាយមានប្រវែង ៣ ហ ម ២០ ។ គេកាត់ប្រើការលើកដំបូងអស់ ៣៩ម៉ែត្រ លើកក្រោយអស់ ៣ដាម៤ ម្ដងទៀតអស់ ៥១ ម តើនៅសល់ខ្សែលួសប៉ុន្មានទៀតក្នុងបន្លាយនោះ?

២.) សំពត់មួយផាប់ប្រវែង ៤៨ ម៉ែត្រ សំពត់៧ផាប់មានប្រវែង ប៉ុន្មាន ហិកតូម៉ែត្រ ?

អាទិត្យទី២.— អំពីហិកតូក្រាម

សូមមើលមេរៀននេះនៅសៀវភៅគ្រូនព្វន្ត អាទិកដ្ឋាន ទំព័រទី៥២ ។

អាទិត្យទី៣.— អំពីហិកតូលីត្រ

សូមមើលមេរៀននេះនៅសៀវភៅដដែល ទំព័រ ៥២ ។

អាទិត្យទី៤.— អំពីទម្ងន់នាឡិ

សូមមើលមេរៀននេះនៅសៀវភៅដដែលត្រង់ទំព័រទី ១១៣ ។ សូមកុំភ្លេចថា ក្នុងមួយនាឡិមាសមានតែ ១០ដំឡឹងទេ ក្រៅពីមាស គេកាប ១៦ ដំឡឹងជាដកាបទើបបានមួយនាឡិ ។ ឯមេរៀនក៏ដូចជាមេរៀនមុនៗដែរ ។

## ធរណីមាណសាស្ត្រ

## អានិត្យទី ១.– បួនជ្រុងទ្រវែង

បន្ទាត់អន្តរប្បាត (médiane) បន្ទាត់ទ្រូង (diagonale)

ប្រដាប់បង្រៀន– ក្រដាសបួនជ្រុង ស្មើនឹងបួនជ្រុងទ្រវែង,

លក្ខណៈបួនជ្រុងទ្រវែង.– ជាចតុរង្គដ៏មានមុមទាំងបួនជាមុមកែង មានជ្រុងឈមប្រវែងស្មើគ្នាពីរ ៗ មាន ទំហំពីរ : គឺទទឹង នឹង បណ្តោយ ឬបាតនឹងកំពស់ ។ បន្ទាត់អន្តរប្បាតនឹងបន្ទាត់ទ្រូងកាត់គ្នាចំពាក់កណ្តាល តែមុមដែលកើតឡើងពីបន្ទាត់ទ្រូងកាត់គ្នាពុំមែនជាមុមកែងដូចនៅកងបួនជ្រុងស្មើឡើយ ។ (យកក្រដាសប្តូរបង្ហាញសិស្សឲ្យឃើញជាក់) ។



មុមទាំង ៤ គឺ ក, ខ, គ, ឃ, សុទ្ធតែមុមកែង

– ជ្រុងឈមគ្នា គឺ កខ ស្មើនឹង គឃ ។ កគ ស្មើនឹង ខឃ ។

បរិវេណៈ កខ + គឃ + កគ + ខឃ ឬ (កខ + កគ) × ២ –

## អានិត្យទី ២.– បរិវេណនៃបួនជ្រុងទ្រវែង–

សេចក្តីណែនាំ.– នាំសិស្សពិនិត្យមើលគំនូរបួនជ្រុងទ្រវែង តើមានទទឹងប៉ុន្មាន ! បណ្តោយប៉ុន្មាន? ដូច្នេះ បរិវេណបួនជ្រុងទ្រវែងកើតពីទទឹង ២ + បណ្តោយ ២ ឬ (ទទឹង ១ + បណ្តោយ ១) × ២

សុំឲ្យសិស្សធ្វើចំណោទឲ្យបានច្រើនបែប . ដើម្បីឲ្យចាំជាក់ ៗ

អានិត្យទី ៣.— រកទំហំណាមួយក្នុងបួនជ្រុងទ្រវែង

សេចក្ដីណែនាំ.— ចូរបញ្ជាក់សិស្សឲ្យចាំច្បាស់ថាបរិវេណក្នុងបួនជ្រុងទ្រវែង គេគិតដោយទទឹងពីរបណ្ដោយពីររួមគ្នា ៗ ពាក់កណ្ដាលបរិវេណ គេគិតតែទទឹង ១ បូកនឹងបណ្ដោយ ១ ៗ ដូច្នេះពាក់កណ្ដាលបរិវេណត្រូវដកប្រវែងទទឹង ១ នឹងប្រវែងបណ្ដោយ ១. ៗ

ពាក់កណ្ដាលបរិវេណ: $$\frac{\text{កខ} + \text{គឃ} + \text{កគ} + \text{ខឃ}}{២}$$ ៗ

---

កុមារដ្ឋាន

គណិត

មេរៀនទី១.- ចំនួនពី ៥០ ដល់ ៥៩

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន

របៀបបង្រៀន.— សុំមើលធ្វើតាមរបៀបរៀនមុនៗ ក្នុងទស្សនាវដ្ដីមុន ៗ

មេរៀនទី២.- ចំនួនដល់ ៥៩

រៀនធ្វើលេខបូកមានលេខពីរខ្ទង់ មានត្រាទុក ។

របៀបបង្រៀន.- សុំមើលតាមរបៀបរៀបចំជាគំរូក្នុងទស្សនា
វដ្តីឆ្នាំទី ៣ លេខ ៥ នៅទំព័រទី ៥០-៥១។

មេរៀនទី ៣.- ចំនួនពី ៦០ ដល់ ៦៩

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន

មេរៀនទី ៤.- ចំនួនដល់ ៦៩

រៀនធ្វើលេខសងមានលេខពីរខ្ទង់មានត្រាទុក ។

## វង្វាស់វង្វាល់

មេរៀនទ១.- អំពីកូនទម្ងន់ គីឡូក្រាម (គ.ក្រ)

មេរៀនទី២.- អំពីកូនទម្ងន់ហិកតូក្រាម (ហ.ក្រ)

មេរៀនទី៣.- អំពីកូនទម្ងន់ដេកាក្រា (ដ.ក្រ)

មេរៀនទី៤.- សាបង្រៀនឡើងវិញ

សុំមើលតាមរបៀបរៀបចំជាគំរូក្នុងទស្សនាវដ្ដីឆ្នាំទី ៣ លេខ ៥ ទំព័រទី ៥២ ៥៣ ។

## បរិញ្ញណាដ្ឋាន

### គព្វគ្គ

មេរៀនទី១.- បញ្ជាក់ចំនួនពី ១ ដល់ ១.០០០ ។

របស់សម្រាប់បង្រៀន. បំពង់សំរាប់ខ្ទង់រាយ - ខ្ទង់ដប់ - ខ្ទង់រយ នឹងបង្កើះ

របៀបបង្រៀន.-

១ – គ្រូថាចំនួនឲ្យសិស្សរៀបបង្កើះដាក់បំពង់ ហើយពន្យល់លេខនៅខ្ទង់និមួយ ៗ ។

២ – គ្រូសរសេរចំនួននៅលើក្ដារខៀនឲ្យសិស្សរៀនអាន ហើយសួរសាករបៀបអានចំនួន ។

៣ – គ្រូថាចំនួនឲ្យសិស្សម្នាក់សរសេរនៅលើក្ដារខៀនហើយសួរសាកអំពីរបៀបអានចំនួន ។

៤ – ការហាត់បញ្ជាក់ដោយមាត់ទទេ.– អំពីរបៀបអានចំនួននិងសរសេរចំនួន

ក– គ្រូបង្អុលចំនួនដែលមានសរសេរនៅលើក្ដារខៀនឲ្យសិស្សអាន ឬ ថាចំនួនឲ្យសិស្សបង្អុល

ខ– គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន

៥ – ការហាត់សរសេរនៅក្នុងសៀវភៅ

សូមតែងការហាត់នេះឲ្យសព្វគ្រប់ផង ។

មេរៀនទី២.– ចំនួនដល់ ១.០០០

រៀនធ្វើលេខបូកឥតត្រាទុកនិងមានត្រាទុក ។

របៀបបង្រៀន.–

១– មតិសំខ្យា.– ឲ្យសិស្សរាប់បន្ថែម ៥ ៗ - ៦ ៗ - ៧ ៗ

២– ពន្យល់របៀបធ្វើលេខ.–

១៣៥រ     ៣៧៩រ

+៣៥២រ     +១៤៥រ

គ្រូពន្យល់នាំសិស្សធ្វើលេខខាងលើនេះ នៅលើក្ដារខៀន

៣– ការហាត់បញ្ជាក់នៅលើក្ដារខៀន.– ឲ្យសិស្សម្នាក់ធ្វើលេខនៅលើក្ដារខៀនឲ្យសិស្សឯទៀតមើល

៤– ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន.– ឲ្យសិស្សធ្វើលេខនៅលើក្ដារឆ្នួន ដើម្បីនឹងបញ្ជាក់ឲ្យច្បាស់ថាសិស្សទាំងអស់ចេះធ្វើលេខហើយឬនៅ

៥– ការហាត់សរសេរនៅក្នុងសៀវភៅ.–

សូមតែងការហាត់នេះផង ។

មេរៀនទី៣.– ចំនួនដល់ ១.០០០

លេខសងចំនួនដុំឥតត្រាទុកនិងមានត្រាទុក ។

មេរៀនទី៤.– ចំនួនដល់ ១.០០០

មេលេខគុណទី ៨

មេរៀនទី៥.– ចំនួនដល់ ១.០០០

រៀនគុណចំនួនដុំទី ៨

មេរៀនទី៦.– សាបង្រៀនអំពីវិជ្ជាដែលបានបង្រៀនក្នុងខែនេះ សូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

## រង្វាស់រង្វាល់

### មេរៀនទី១.– អំពីដេស៊ីម៉ែត្រ (ដ.ម.)

របស់សម្រាប់បង្រៀន.- ម៉ែត្រ-ដេស៊ីមែត្រក្រោះបង្កើះប្រវែង ៣ ដ.ម ។ ៥ ដ.ម ។

របៀបបង្រៀន.–

១ ការពិនិត្យរង្វាស់

២- ការហាត់ស្មានទីងវាស់បញ្ជាក់

៣– ការហាត់គិត

៤– ការហាត់សរសេរនៅក្នុងសៀវភៅ សូមមើលតាមរបៀបក្នុងទស្សនាវដ្ដីឆ្នាំទី ៣ លេខ ៥ ទំព័រទី ៥៧ ។

ការចំណាំ.- កុំច្រឡំការហាត់គិតក្នុងរង្វាស់រង្វាល់នឹងការហាត់គិតក្នុងនព្វន្ត ដូចជា ៣ ដ.ម + ៥ ដម = ឬ ១៥ ដ.ម – ៧ ដ.ម = ។ ៧ ដម × ៥ = .. ។ នេះជាការហាត់ក្នុងនព្វន្ត ។ ឯការហាត់ក្នុងរង្វាស់-

រង្វាល់ត្រូវមានការផ្ទេរជាដកបដូចជា ១៧ ដ.ម + ៣ម =....ដ.ម ។

៣ម – ១២ដ.ម=..ដ.ម ។ ៥ដ.ម × ៦ =..ម ។

មេរៀនទី ២.– អំពីដេស៊ីលីត្រ - ដេស៊ីក្រាម ។

មេរៀនទី ៣.– អំពីសង្ទីម៉ែត្រ - សង្ទីលីត្រ - សង្ទីក្រាម ។

មេរៀនទី ៤.- - អំពីមីលីម៉ែត្រ - មីលីក្រាម ។

មេរៀនទី ៥.– អំពីផ្ទៃត្រីកោណ ។

---

អាទិកដ្ឋាន

## វិត្តស្វាធ្យាយន៍

### ឧស្សាហកម្ម

អាទិត្យទី១ ការស្លប្រេង

មានប្រេងសំរាប់បរិភោគនឹងប្រេងសំរាប់ធ្វើការផ្សេងៗ ឯប្រេងសំរាប់អាស្រ័យនោះធ្វើនឹងដូង សណ្តែកដី ល្ង ។ ប្រេងសំរាប់ធ្វើការផ្សេង ៗ ធ្វើនឹងគ្រាប់ល្ហុងខ្វង កប្បាស ។

ដើម្បីនឹងស្លប្រេងគេយកសាច់ដូងចេញអំពីសំបក គេបំបែកជាហើយ

គេយកទៅហាលថ្ងៃ រួចគេយកទៅបុកដាំរំលាស់គ្រាប់នោះក៏ឡើងទៅជាម្សៅ ៗ គេយកម្សៅនោះទៅសង្កត់ធ្វើជានំ ៗ កាកសាច់បានជាជីយ៉ាងល្អ កាកខ្លះសោះអស់ទៅគេឲ្យសត្វស៊ី ៗ

ក្នុងទសព្វាហកម្មបាកំង គេស្ងូប្រេងដូងជាក្នុងទសព្វាហកម្មខ្មែរដែរ ប៉ុន្តែបាកំងយកលលាដ៍សាច់ដូងទៅកិនទឹងម៉ាស៊ីន រួចគេយកម្សៅទៅស្ងោរក្នុងឆ្នាំងខ្ទះមួយដែលគេយកប្រេងបានយ៉ាងងាយ ៗ

អាទិត្យទី ២.– ការធ្វើកៅស៊ូ

សេចក្តីសង្ខេប. កៅស៊ូមានកំណើតនៅប្រទេសអាមេរិកខាងត្បូង មានជ័រស ដើមវាដុះបានល្អនៅប្រទេសក្តៅ ៗ គេយកជ័រកៅស៊ូបាន់រវាំងដាំបាន ៦ ឆ្នាំហើយៈគេយកជ័រនោះធ្វើជាបន្ទះនៅក្នុងបំការកៅស៊ូតែម្តង ៗ បន្ទះកៅស៊ូនេះគេសំអាតចំអិនជាថ្មីទៀតក្នុងរោងទសព្វាហកម្មធំ ១ ៗ

ប្រយោជន៍កៅស៊ូ.– កៅស៊ូលាយទឹងជាតិមនោសិលា (ម្នាស់សិលា) ទឹងត្បូងឬទឹងស្ពាន់ធ័រ ប្រើការបានច្រើនយ៉ាងណាស់ ៖ បំពង់ ខ្សែ សំពត់ កៅស៊ូគង់ ៗ ល ៗ បើគេចង់ឲ្យរឹង គេថែមស្ពាន់ធ័រឲ្យច្រើន ៗ

អាទិត្យទី ៣.– ការធ្វើក្រដាស

ក្រដាសកើតពីសរសៃរុក្ខជាតិផ្សេង ១ ដូចជាកប្បាសចំបើងឬសាច់ឈើ ៗ នៅប្រទេសឥណ្ឌូចិន គេធ្វើទឹងដើមមន ដើមឬស្សី ដើមស្បូវ

ចំបើងឬកំណាត់សំពត់ចាស់ ៗ ៗ គេយកជាតិទាំងនេះមកចិញ្ច្រាំហើយ ស្ងោរជាមួយទឹកក្បុងឲ្យស្រស ៗ គេរាលបបរនេះលើផ្ទៃកំណាត់ស្ដើងហាលឲ្យស្ងួតកើតជាក្រដាស ៗ ក្រដាសសរសេរមានលាយជាតិកាវផង ក្រដាសជ្ដិតគ្មានជាតិកាវទេ ៗ

អាទិត្យទី ៤.- ឧស្សាហកម្មកើតពីឈើ

ឈើមានពីរបំពូក ៖ ឈើលេខ ១ និងឈើប្រើការធម្មតា

១- ឈើលេខ ១ ដូចជាបេង នាងនួន សំរាប់ធ្វើតុ តាំងប្រណីត ៗ

២- ឈើប្រើការធម្មតាដូចជាក្រាបឈើតាលសំរាប់ធ្វើគ្រឿងផ្ទះនិងគ្រឿងដទៃទៀតជាច្រើន ៗ

៣- ឬស្សីមានប្រយោជន៍ច្រើនយ៉ាង គ្រឿងផ្ទះ នេសាទឧបករណ៍ សាទុបករណ៍ ខេត្តបករណ៍ ៗ

៤- ប្រយោជន៍ផ្សេងៗទៀតនៃដើមឈើ ធ្វើធ្យូង ឈើគូស យកជ័រប្រើការផ្សេងៗ ក្នុងការធ្វើទឹកអប់ ធ្វើប្រេង ធ្វើថ្នាំ ៗ សំបកកោងកាងប្រើក្នុងការសម្លាប់ស្បែក មានសំបកឈើ ខ្លឹមឈើ និងផ្លែឈើច្រើនសំរាប់ប្រើក្នុងការជ្រលក់សំពត់ ដូចជាសំបកស្លាប់ ព្រហ្មូត ផ្លែម៉ាក់ក្លឿ ផ្លែដម្ពូ មើមរមៀត.....ៗ

អាទិតដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី ១.– អំពីចំណីអាហារ

ចូរអាស្រ័យតែចំណីណាដែលនាំឲ្យសុខសប្បាយខ្លួន ។ បាយជាអាហារងាយរំលាយបំផុត អង្ករមានទុជាសេណាស់ បន្លែស្រស់ទាំងផលានុផលជាចំណីត្រជាក់ ។

យើងអាស្រ័យសាច់គោ កូនគោ ជ្រូក ចៀម ទន្សាយ មាន់ ត្រីទាំងសត្វព្រៃ ។

ទឹកដោះគោជាចំណីចំណានជាងគេដល់ក្មេងតូចៗ តែគេតោងតែដាំជាមុន ។

ទឹកដាំជាភេសជ្ជៈវិសេសបំផុត ។ នៅប្រទេ.បត្ណូចិនគេច្រើនប្រើទឹកតែជាភេសជ្ជៈៗ សុរាជាថ្នាំពុលតោងយើងតមកុំឲ្យសេពសុរាទាំងមេរ័យ

### អាទិត្យទី ២.– អំពីរុយ

១.– កំណើតនៃរុយ.– រុយវាពងនៅលើដីដី លើគំនរសំរាម លើលាមក លើកាកអាហារស្អុយ លើគំនរធំនៅកន្លែងស្មោកគ្រោក ។ វាពង

តែ ៨ ថ្ងៃកើតបានជារុយពេញរូបរាង ។ តែក្នុង ៣ ខែៈនៅរដូវក្ដៅ រុយមួយអាចបែងចេញជាកូនចៅបានប្រហែល ៥ លាន ។

២ - ការអន្តរាយបណ្ដាលអំពីរុយ.– រុយចម្លងរោគផ្សេងៗ អាចបណ្ដាលឲ្យឈឺជម្ងឺគ្រុនធ្ងន់ មួល អាសន្នរោគ ក្អករបេងរីងរៃ រាក ឈឺភ្នែក ។

អាទិត្យទី ៣ ថ្ងៃទី ៤.– បំពីរុយ (ត)

៣ - កិច្ចការពារនឹងរុយ ត្រូវគ្របចំណីអាហារបរិភោគឲ្យជិត ត្រូវចាក់សំរាមនឹងកាកអាហារឲ្យឆ្ងាយពីផ្ទះ ហើយខសប្ដាហ៍បោសសំអាតទីកូមិពល់ព្រឹកត្រូវកុំឲ្យក្មេងដេកវាល ត្រូវដាក់មុងឲ្យវាដើម្បីកុំឲ្យរុយមកទំមាត់ឬភ្នែក ។

---

បរិច្ឆណដ្ឋាន

## វត្ថុស្វាធ្យាយន៍

អាទិត្យទី១. ១– ជាតិថ្ម

វត្ថុសម្រាប់បង្រៀន - ថ្មបាយក្រៀម - ថ្មកែវ - ថ្មកំបោរ - គ្រួស- ដីខ្សាច់ - ដីឥដ្ឋ - ដីស ។

នាំសិស្សពិនិត្យមើលថ្មទាំងអស់នេះ ហើយធ្វើតាមរបៀបបង្រៀន
វត្ថុស្ថាញ្យាយចុះ (ថ្មខ្លះមានទ្រង់ជាផ្ទាំងថ្មជាដុំធំៗនៅក្នុង ខ្លះទៀតជាកំ
ទេចល្អិតដូចជាគ្រួសឬដីខ្សាច់ ថ្មនៅក្នុងដីគឺថ្មនេះហើយដែលជាសំបក
នៅផែនដី ដូចម្តេចបានជាថ្មខ្លះសណ្ឋានជាដុំ ខ្លះជាកំទេច កាលពីផែនដី
ចាប់កំណើតឡើង ថ្មទាំងអស់គឺជាផ្ទាំងៗ ប៉ុន្តែដោយត្រូវកំដៅត្រជាក់ជា
ញឹកញយថ្មនោះប្រេះបែកនឹងខ្យល់នឹងទឹកភ្លៀង កំប្រេះកំទេចថ្មនោះ នាំ
យកមកបាក់ទីទំនាបកើតឡើងជាដីដែលគេដាំដំណាំនៅលើសព្វថ្ងៃនេះ ។

សូមគ្រូតែងសេចក្តីសង្ខេបឲ្យសិស្សរៀនចាំចុះ

## អាទិត្យទី២.— អំពីឫកំបោរនិងធ្យូងថ្ម

សូមគ្រូពន្យល់អំពីរបៀបដុតកំបោរ នឹងរបៀបជីកយកធ្យូងថ្ម
ហើយនឹងយកធ្យូងថ្មមកប្រើដុតអ្វីផ្សេងៗ ។

## អាទិត្យទី៣. អំពីលោហធាតុ

វត្ថុសម្រាប់បង្រៀន ដែក ស្ពាន់ ស្ពាន់ស សំណ សំណប៉ា
ហាំង សង្កសី ប្រាក់ មាស ។

សុំគ្រូពន្យល់ថា លោហធាតុអស់ទាំងនេះកើតនៅក្នុងដី នៅជ្រៅ
ណាស់ ដែលនឹងយកមកពីក្នុងដីគេជីករណ្តៅជ្រៅគាស់កកាយយកមក
លោហធាតុនៅក្នុងដីមិនសុទ្ធទេមានលាយនឹងវត្ថុឯទៀត មានលោហ-

ធាតុតែពីរទេសុទ្ធ គឺមាសនឹងប្រាក់ លោហធាតុមានពន្លឺខ្លះតិចខ្លះច្រើន លោហធាតុដុំ បត់បែនឬហូតជាខ្សែបានទាំងអស់ ។ លោហធាតុដាច់ណាស់ មិនពុកមិនបាក់ងាយទេ ប៉ុន្តែរលាយដោយកំដៅទាំងអស់ លោហធាតុនាំកំដៅឆាប់ណាស់ ។

សេចក្តីសង្ខេប– លោហធាតុ គឺដែក ស្ពាន់ សំណ សង្កសី ទង់ហ្វា ទង់ដែង មាស ប្រាក់ លោហធាតុកើតក្នុងដី ។ លោហធាតុទាំងអស់នេះមានពន្លឺ ដំបត់បែនបាន ហូតជាខ្សែបាន ។ លោហធាតុដាច់មាំ រលាយបានហើយនាំចំហាយតូចណាស់

អាធិត្យទី ៤.– សុំគ្រូបញ្ជាក់ឲ្យមែនទែនអំពីមេរៀនទាំងអស់ ដូចមានអធិប្បាយខាងលើនេះ

## វិធីបង្ការរោគ

សើរើរៀនពីថ្ងៃមុនមកតាំងពីចូលរៀនខែកញ្ញាមក

———

### កុមារដ្ឋាន

## វិត្តស្វាធ្យាយន៍

## អាធិត្យទី១.— អំពីរុក្ខជាតិ

វត្ថុសម្រាប់បង្រៀន កូនឈើ១ដើមកំពស់កន្លះម៉ែត្រ ស្មៅល្ពឹង. ទៀតច្រើនមុខ ។

ពាក្យសួរ— រុក្ខជាតិដុះនៅឯណា ? រុក្ខជាតិមានជីវិតឬឥតជីវិត ? នាំសិស្សពិនិត្យមើលកូនឈើ ១ ដើមមានប៉ុន្មានចំណែក ? នាំសិស្សពិនិត្យមើលឫស ឫសដែលវែងធំជាងគេចុះក្រោមហៅឫសអ្វី ? នៅសងខាងឫសកែវមានឫសអ្វីទៀត នាំសិស្សឲ្យពិនិត្យមើលរោមឆ្មារ ៗ ដែលដុះចេញពីឫសកែវឫសរយាង រោមនេះហៅថារោមស្រូប សំរាប់ស្រូបជញ្ជក់យកអាហារពីក្នុងដី ។

នាំសិស្សពិនិត្យមើលរុក្ខជាតិទាំងអស់ដូចគ្នាឬមួយខុសគ្នា ដើមឈើណាខ្លះដែលមានដើមមានជាតិឈើរឹង (ស្វាយ ក្រូច) ដែលមានដើមទន់ដូចស្មៅ (ស្រូវ-ពោត)

ពិនិត្យមើលស្លឹកមានពណ៌ដូចម្តេច ? ជាតិអ្វីដែលនាំស្លឹកឲ្យមានពណ៌បៃតង ? មានជាតិមួយពណ៌បៃតង ជាតិនេះមានប្រយោជន៍សំខាន់ក្នុងការចិញ្ចឹមជីវិតនៃរុក្ខជាតិទាំងឡាយ ។

ពីមុខការនៃឫស ដើម ស្លឹក ។

វត្ថុសម្រាប់បង្រៀន កូនឈើ១ដើម ស្លឹកឈើត្រាំស្រាទុកមកពីថ្ងៃមុន ។

ពាក្យសួរ– ឫសមានប្រយោជន៍អ្វីខ្លះដល់រុក្ខជាតិ ឫសសម្រាប់ភ្ជាប់ដើមទៅនឹងដី ហើយនឹងស្រូបជញ្ជូនយកជាតិអាហារពីក្នុងដី នាំសិស្សពិនិត្យមើលរោមស្រូប ។ ឯរោមស្រូបនេះជញ្ជូនអាហារយ៉ាងដូចម្ដេច គ្រូយកក្រដាសផ្ដិតមួយ សន្ទឹកមកជ្រលក់ក្នុងទឹកក្រហមឲ្យសិស្សសង្កេតមើល ទឹកក្រហមដែលជ្រាបជាមះឡើងមកលើក្រដាសផ្ដិត ។ ឯរោមស្រូបក៏ស្រូបយកអាហារដែលរលាយទៅក្នុងទឹកដូច្នេះដែរ ។ ទឹក (ជ័រ) ដែលឫសស្រូបយកពីដីនោះទៅឯណាទៀត ? ជ័រដែលឫសស្រូបមកនោះក៏ជ្រាបតាមដើមមកស្លឹក គ្រូយកដីសមួយដុំជ្រលក់ទៅក្នុងទឹកខ្មៅ នាំសិស្សមើលទឹកខ្មៅដែលជក់ឡើងមកលើ ជ័រឈើក៏ជក់ឡើងដូច្នេះដែរ ដើមសម្រាប់នាំជ័រឡើងមកក្នុងស្លឹក ។ ស្លឹកធ្វើការអ្វីជាប្រយោជន៍ដល់រុក្ខជាតិ នៅក្នុងស្លឹកមានជាតិមួយពណ៌បៃតង ។ បង្ហាញសិស្សមើល ជាតិនេះឯងស្រូបយកធាតុមួយពីក្នុងខ្យល់អាកាសយកមកផ្សំនឹងជ័រ ។ រុក្ខជាតិទាំងឡាយដកដង្ហើមតាមស្លឹក ហើយបញ្ចេញចំហាយទឹកតាមស្លឹកដោយសារធាតុផ្សេងៗ ដែលស្លឹកនាំយកមកលាយជាមួយនឹងជ័រៗនេះក៏ឡើងខាប់បរិសុទ្ធឡើងរូបទៅ ជ័រនេះក៏ជ្រាបចូលទៅសព្វគ្រប់ចំណែករុក្ខជាតិនាំអាហារទៅចិញ្ចឹម ។

អាទិត្យទី២.– អំពីផ្កានិងផ្លែ

វត្ថុសម្រាប់បង្រៀន ផ្កាទទឹមឬផ្កាត្របែក ក្ដិបផ្លែទទឹមឬត្របែក ។

ពាក្យសួរ– នាំសិស្សពិនិត្យមើលផ្កា មានប៉ុន្មានចំណែក ? ស្រទាប់ក្រៅរួមគ្នាជាកញ្ចុំស្រទាប់ក្រៅ ស្លឹកស្រទាប់ក្នុងរួមជាកញ្ចុំស្រទាប់ក្នុង គ្រូបេះសន្ទឹកនេះចោលចេញអស់ ។ ខាងក្នុងស្លឹកស្រទាប់មានអ្វី ? ។ នៅកណ្ដាលផ្កាមានបំពង់មួយការីដូចជាដប នៅលើបំពង់នេះមានទងខ្នារ ។ ពកចុងបែបដូចជាថង់ គ្រូវះថង់នោះហើយនាំសិស្សពិនិត្យមើលលំអងផ្កា ដែលមាននៅក្នុងផ្កានោះ ។

គ្រូវះបំពង់ផ្កាបង្ហាញសិស្សមើល ។ មានឃើញអ្វី ។ នៅក្នុងបំពង់នោះមានគ្រាប់តូច ៗ ដល់ផ្កានោះចាស់ទៅ ផ្កានោះនឹងផ្លាស់រូបដូចម្ដេចទៀត ? ដល់ផ្កានោះទុំទៅ ថង់ផ្កាក៏ប្រេះធ្លាយលំអងផ្កាក៏ធ្លាក់ចុះចូលទៅក្នុងបំពង់ផ្កា ហើយនឹង គ្រាប់ដែលនៅខាងក្នុង ។ ផ្កាក៏ចាប់ប្រែរូបស្លឹកស្រទាប់ ហើយនឹងទងលំអងផ្កាដែលជាគួរផ្កាញីនោះក៏រគងឡើង ។ បង្កើតជាផ្លែនៅខាងក្នុងគ្រាប់តូច ១ នោះក៏កើតជាគ្រាប់ផ្លែ គ្រូវះក្ដិបហើយនឹងផ្លែទទឹមនាំសិស្សពិនិត្យមើល ។

## ២ អំពីបណ្ដុះគ្រាប់

វត្ថុសម្រាប់បង្រៀន.- ឲ្យសិស្សយកគ្រាប់សណ្ដែកទៅបណ្ដុះ

នៅក្នុងពានមួយ វេលាមួយគាត់ទុកជាមុន ហើយឲ្យរកគ្រាប់អំពិល គ្រាប់ស្វាយទុកបន្ទៀន ។

ពាក្យសួរ– នាំសិស្សពិនិត្យគ្រាប់សណ្ដែក ឬគ្រាប់ស្វាយ ពុះគ្រាប់នោះមើលនៅខាងក្នុងមានអ្វីខ្លះ ? ។ មានសាច់សនៅជាប់នឹងសាច់នោះមានពូជស្វាយ ឬសសណ្ដែកតូចមួយ បើយកមកពិនិត្យនឹងឃើញមានដើមឬសហើយនឹងត្រួយតូច ៗ ពូជនេះរស់ដោយសារអ្វី ? ពូជរុក្ខជាតិនេះមានអាយុចិញ្ចឹមជីវិតរស់នៅដោយជាតិអាហារ ដែលមាននៅក្នុងសាច់ក្នុងគ្រាប់ ។

ហេតុដូចម្ដេចបានជាពូជនោះដុះធំឡើងបាន បើយើងយកគ្រាប់សណ្ដែកទៅកប់ក្នុងដីខ្សាច់យើងស្រោចទឹក ហើយដាក់ហាលកំដៅថ្ងៃ ទឹកក៏ជ្រាបចូលទៅក្នុងគ្រាប់ ៗ នោះក៏រីកធំឡើង សំបកក្រៅក៏ប្រេះ ពូជរុក្ខជាតិនៅខាងក្នុងក៏ចាក់ឬសចុះទៅក្នុងដី ដើមក៏លូតវែងឡើង ហើយទ្រគ្រាប់ផុតឡើងចេញពីដី ស្លឹកក៏លូតលាស់ចេញ ។ កាលណាដល់ជាតិអាហារ នៅក្នុងគ្រាប់នោះអស់ទៅ កូនសណ្ដែកនោះដុះឬសកាន់តែច្រើនហើយ មានប្រដាប់សព្វគ្រប់អាចនឹងចិញ្ចឹមជីវិតបានខ្លួនឯង សំបកគ្រាប់នោះក៏ជ្រុះទៅ ដើមឈើណាខ្លះដែលដុះមកអំពីគ្រាប់ដូច្នេះ ។

អាទិត្យទី ៣ – ១ អំពីស្រូវ – ២ អំពីដំឡូង

អាទិត្យទី ៤ – ១ អំពីកប្បាស – ២ អំពីអំពៅ

កុមារដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី ១.– ការសំអាតសំពត់

សំពត់ដែលប្រើប្រាស់នៅផ្ទះក្រៅពីខោអាវនោះ គឺក្រមា កន្សែងជូតមុខ កំរាលតុ កំរាលពូក ស្រោមខ្នើយ ភួយ-មុង ។ របស់អស់ទាំងនេះ គេតែងតែរក្សាឲ្យស្អាតទើបប្រើបានយូរ ហើយគ្មានចៃឬសង្កើចអ្វីមកនៅបានឡើយ ។ កន្សែងជូតមុខ ក្រមា កំរាលតុ ស្រោមខ្នើយ ត្រូវបោកសាប៊ូយ៉ាងតិចក្នុងមួយអាទិត្យម្ដង កំរាលពូក ភួយត្រូវត្រដាងហាលថ្ងៃជាញឹកញយជាមួយនឹងពូកឬកន្ទេល ម្យ៉ាងទៀតក្រមាឬកន្សែងជូតមុខដែលសើមឬទទឹក ត្រូវលាហាលថ្ងៃកុំឲ្យទុកនៅទទឹកជុំគ្នាផ្អូម ។ ភួយ មុងនឹងកំរាលដែលក្រាល ត្រូវស្ងោរទើបបានស្អាតជ្រះក្អែលញ៉េស សត្វគ្រប់ ។

### អាទិត្យទី ២.– ការសំអាតសំលៀកបំពាក់

វត្ថុសម្រាប់បង្រៀន សាប៊ូការបូណាតដឺសូត ទឹកក្ដៅទឹកត្រជាក់ប្រេងដូង យកប្រេងបន្តិចចាក់ទៅក្នុងទឹកត្រជាក់កូរវិតហើយនាំសិស្សមើល ។

ប្រេងអណ្តែតត្រានៅលើទឹក បើចាក់ប្រេងនោះទៅក្នុងទឹកក្តៅវិញ ប្រេងនោះក៏ធាប់រលាយដែរ ។ យកទឹកសាប៊ូត្រជាក់ឬក្តៅវិញ ហើយចាក់ប្រេងបន្តិចទៅក្នុងទឹកសាប៊ូ ប្រេងនោះរលាយបាត់ ។ ហេតុនេះហើយបានជាត្រូវបោកខោអាវនឹងសាប៊ូ ព្រោះសាប៊ូ អាចនឹងរំលាយជាតិប្រេងខ្លាញ់នឹងក្អែល ហើយសម្លាប់មេរោគបាន ។

បើយកការបូណាតដឺសូ៊តបន្តិចដាក់ក្នុងទឹកក្តៅនឹងរលាយបាត់ ទឹកនោះអាចនឹងរលាយខ្លាញ់ពូកែជាងសាប៊ូទៅទៀត ហេតុដូច្នេះបានជាគេស្ងោរសំពត់ដែលក្រាស មុននឹងបោកត្រូវរើសដាក់ដោយពួកសំពត់អាវស សំពត់អាវមានពណ៌ សំពត់ព្រែនឹងសំពត់មានរោម ។

១- សំពត់អាវដែលត្រូវយកទៅស្ងោរទើបបានជ្រះល្អ

២– សំពត់ដែលមានពណ៌ ត្រូវបោកតែនឹងសាប៊ូហើយលាងទឹកឲ្យស្អាតហាលថ្ងៃ ។

## អាធិត្យទី ៣ - ការសំអាតសំលៀកបំពាក់ (ត)

៣– សំពត់ព្រែនឹងសំពត់ធ្វើអំពីរោមសត្វ ឯសំពត់អស់ទាំងនេះមិនត្រូវយកទៅស្ងោរឬឲ្យត្រូវទឹកក្តៅខ្លាំងឬមួយញីខ្លាំងពេកនោះទេ ។

គេយកសាប៊ូទៅលាយនឹងទឹកក្តៅល្មម គេយកសំពត់នោះទៅត្រាំ

ហើយគេប្រញាប់រួចគេលាងទឹកក្តៅ គេតូតមិនញាប់មួលហើយយកទៅ ត្រដាងហាលកបដើម្បីកុំឲ្យរួញ ។

បើចង់លាងសំពត់ពេមហៀម គេយកទឹក " អាមូនីញាក់ " បន្តិច ទៅដាក់ក្នុងទឹកសាប៊ូរួចទើបគេបោក,

៤. របៀបលាងជំរះស្នាមប្រឡាក់ បើបោកនឹងសាប៊ូឬស្វារ ពុំជ្រះគេប្រើ

ក- ទឹកហ្សាវែល ជម្រះស្នាមទឹកខ្មៅឬឈើ

ខ- ប្រេងសាំងរំលាយជាតិខ្លាញ់ ។

គ- ទឹកអាម៉ូនីញាក់ ជំរះក្អែល ។

## អាទិត្យទី ៤.- របៀបស្ងោរសំពត់អាវ

គេយកសំពត់អាវទៅត្រាំទឹកត្រជាក់ យកសាប៊ូមកដុះត្រង់កន្លែង ណាដែលមានក្អែលក្រខ្វក់ នៅបាតឆ្នាំងគេដាក់ (កាបូណាតដឺសូត) គេដាក់ សន្ទះឆ្នាំងទៅក្នុងឆ្នាំង គេរៀបសំពត់អាវដាក់ទៅក្នុងសំពត់ក្រាស់ពីក្រោម សំពត់ស្តើងពីលើ គេចាក់ទឹកពាក់កណ្តាលឆ្នាំងទើបដុតភ្លើង គេទុកឲ្យ ពុះចំនួន ២ ម៉ោង ដល់ត្រជាក់ទៅគេយកសំពត់នោះមកញីដុះសាប៊ូថែម ទៀត បើនៅក្រខ្វក់រួចគេយកទៅលាងទឹកទើបយកទៅហាលថ្ងៃ ។

# លោកឥតិ

## សំរាប់គ្រប់ថ្នាក់

( ឥតពី ១ ជ្ជ )

ប្រការ៣ – នរណាមានអំណាចចាប់? ដើម្បីនឹងចាប់ត្រូវធ្វើតាមរបៀបដូចម្តេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់?

សេចក្តីត្រង់នេះមានករណី ២ យ៉ាង:

១) បទឧក្រិដ្ឋឬមជ្ឈិមដែលទាន់ជាក់ស្តែង

២) ក្រៅពីបទឧក្រិដ្ឋឬមជ្ឈិមដែលទាន់ជាក់ស្តែង

១– បទឧក្រិដ្ឋឬមជ្ឈិមដែលទាន់ជាក់ស្តែង -

ក្នុងបទឧក្រិដ្ឋឬមជ្ឈិមដែលទាន់ជាក់ស្តែង នរណាក៏ដោយមិនចាំតែជានាយភ្នាក់ការក្រុមព្រះនគរបាលយុត្តិធម៌ទេ អាចចាប់អ្នកប្រព្រឹត្តបទល្មើសបាន ។ ច្បាប់បើកអំណាចឲ្យឯកជនមានសិទ្ធិចាប់អ្នកប្រព្រឹត្តបទល្មើសដែលទាន់ជាក់ស្តែងហើយ នាំទៅប្រគល់ឲ្យនាយភ្នាក់ការក្រុមព្រះនគរបាល (មាត្រា៤៨២ ក.ព និងមាត្រា៥៥ ក.ព) ។

២)– ក្រៅពីបទឧក្រិដ្ឋឬមជ្ឈិមដែលទាន់ជាក់ស្តែង

ក្រៅពីបទឧក្រិដ្ឋឬមជ្ឈិមដែលទាន់ជាក់ស្តែង មានត្រឹមតែនាយភ្នាក់ការ

ក្រុមព្រះនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ដែលនឹងចាប់មនុស្សបាន ប៉ុន្តែក៏-ត្រូវឲ្យមានលក្ខណៈណាមួយក្នុងបណ្តាលក្ខណពីរយ៉ាងដូចតទៅនេះ ៖

ក) មានបង្គាប់ពីតុលាការឬ

ខ) បានទទួលបណ្តឹង ។

ក) នាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ចាប់ដោយមានបង្គាប់ពីតុលាការ (មាត្រា ២៤៣ ក.ព )

ភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ ត្រូវចាប់មនុស្សណាដែលមានដីកានាំខ្លួនឬដីកាចាប់ខ្លួន ដែលតុលាការមុខក្រសួងចេញតំរូវឲ្យចាប់នឹងមនុស្សណាដែលមានសាលក្រមកាត់ទោសដាក់គុកផុតរយៈឧទ្ធរណ៍ ។ ដីកានាំខ្លួនជាសំបុត្រដែលតុលាការមុខក្រសួង (តាមធម្មតាសុកាចាបុរស ចេញបង្គាប់ឲ្យភ្នាក់ងារកំឡាំងអាជ្ញាទាំងពួង នាំខ្លួនអ្នកត្រូវចោទមកជូនតុលាការនោះ ។ ដីកានាំខ្លួននឹងចេញបានតែក្នុងរឿងឧក្រិដ្ឋឬមជ្ឈិមទម្ងន់ហើយបើអ្នកជាប់ចោទគ្មានទីលំនៅខ្ជាប់ ឬបើគួរខ្លាចក្រែងអ្នកត្រូវចោទ គេចរត់បាត់ខ្លួនឬកាលបើអ្នកត្រូវចោទមិនបានចូលទៅសាលាតាមដីកាបង្គាប់ឲ្យចូលខ្លួន (មាត្រា១៧៥ - ១៧៤ ក. ព. ព. )

ភ្នាក់ងារដែលទទួលសំរេចតាមដីកានាំខ្លួន ត្រូវបង្ហាញដីកានោះទៅអ្នកត្រូវចោទ ហើយប្រគល់ចុងដីកាឲ្យទៅផង (មាត្រា១៧៦ ក.ព.ព)

រួចត្រូវនាំខ្លួនអ្នកត្រូវចោទទៅជូនតុលាការមុខក្រសួង ដើម្បីសាកសួរក្នុង-រយៈពេល២៤ម៉ោង (មាត្រា១៨០ ក. ព. ព.) ។ ដល់អ្នកត្រូវចោទចូល-ខ្លួនដល់តុលាការដែលបានចេញដីកានាំខ្លួន ហើយដីកានាំខ្លួននោះអស់អំណាចតែប៉ុណ្ណោះ ។ តុលាការនោះនឹងបើកលែងឲ្យនៅក្រៅឃុំក៏បាន-បើនឹងដាក់ឲ្យឃុំខ្លួនក៏បាន តែត្រូវចេញដីកាមួយទៀត ហៅថាដីកាឃុំខ្លួន (មាត្រា ១៨១ ក. ព. ព. ) ។

ដីកាចាប់ខ្លួន បើអ្នកត្រូវចោទគេចបាត់ខ្លួននោះតុលាការចេញដីកាឲ្យចាប់ ដោយបានសេចក្តីយល់ព្រមជាមុនពីក្រុមអយ្យការ ។ ដីកានេះបើកអំណាចឲ្យភ្នាក់ងារដែលចាប់អ្នកត្រូវចោទនាំខ្លួនត្រង់ទៅគុកតែម្តង ។

(មាត្រា ១៨២ នឹង ១៨៣ ក. ព.)

១) នាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ចាប់ដោយបានទទួលបណ្តឹង អ្នកចេះច្បាប់ខ្លះយល់ថាកាលបានទទួលបណ្តឹងដោយត្រឹមត្រូវជា-ជនណាបានប្រព្រឹត្តបទឧក្រិដ្ឋឬមជ្ឈិម នាយក្រុមព្រះនគរបាលយុត្តិធម៌មានសិទ្ធិចាប់ជននោះមកសាកសួរ ធ្វើសេចក្តីកត់ហេតុបញ្ជូនទៅព្រះ-រាជអាជ្ញាព្រមទាំងជននោះផងឬនឹងបើកលែងជននោះសិនហើយបញ្ជូនតែពាក្យកត់ហេតុទៅក៏បានដែរ ។ អ្នកដែលយល់ដូច្នេះអាងដល់មាត្រា៣៩ ក. ព. ព. ដែលមានសេចក្តីដូចតទៅនេះ ៖

"មុខក្រសួងក្រុមព្រះនគរបាលយុត្តិធម៌ ត្រូវស៊ើបរកបទល្មើសជាឧក្រិដ្ឋ មជ្ឈិម និងលហុ ប្រមូលភស្តុតាង និងជូនខ្លួនមនុស្សដែល ប្រព្រឹត្តបទល្មើសទាំងនោះ ទៅសាលាដែលបំពាក់ផ្ដើទោសមនុស្សដែលប្រព្រឹត្តបទល្មើសនោះ ។

តាមយោបល់អ្នកខ្លះទៀត បទបញ្ញត្តិនៃមាត្រានេះមិនជាក់ច្បាស់គ្រប់គ្រាន់ទេ ព្រោះគ្មានមាត្រាឯទៀតមកប្រកបសេចក្ដីផង ថានាយក្រុមព្រះនគរបាលយុត្តិធម៌មានសិទ្ធិចាប់មនុស្សកាលគ្រាន់តែបានទទួលបណ្ដឹង ។ គេអាចយល់បានថា អ្នកតែងច្បាប់មានបំណងបើកអំណាចឲ្យនាយក្រុមព្រះនគរបាលយុត្តិធម៌ចាប់អ្នកប្រព្រឹត្តបទល្មើសបានតែរឿងក្នុងបទល្មើសដែលទាន់ជាក់ស្ដែង និងកាលបានទទួលបង្គាប់ពីតុលាការមុខក្រសួង ។

នាម៉ឺន និងភ្នាក់ងាររាជការ ដែលជានាយក្រុមព្រះនគរបាលយុត្តិធម៌មានសិទ្ធិចាប់មនុស្សឬទេ ? ត្រង់នេះមានសេចក្ដីយល់ផ្សេងៗ ព្រោះគ្មានបទបញ្ញត្តិណាសំដែងឲ្យជាក់ច្បាស់ ។

ប្រការ ៤ .— នរណាមានអំណាចឃុំឃាំង ដើម្បីនឹងឃុំឃាំងត្រូវធ្វើតាមរបៀបដូចម្ដេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់ ។

មានតែតុលាការតែប៉ុណ្ណោះ ដែលមានអំណាចឃុំឃាំង ។

ដើម្បីនឹងឃុំឃាំងបាន តុលាការមុខក្រសួងត្រូវចេញសាលក្រមកាត់

ទោសដាក់គុក ឬចេញដីកាតុលាការ ។ ដីកាតុលាការដែលបើកអំណាចឲ្យឃុំឃាំងបាននោះ គឺដីកាចាប់ខ្លួននិងដីកាឃុំខ្លួន ។

ឯដីកាឃុំខ្លួន គឺជាពាក្យបង្គាប់ឲ្យទទួលខ្លួនអ្នកត្រូវចោទទៅឃុំទុកក្នុងគុក ។

ការចេញដីកាឃុំខ្លួននេះ មិនមែនជាការផ្តាលឬជាការដាក់ទណ្ឌកម្មទេ គឺជាការប្រយ័ត្ន កុំឲ្យត្រូវចោទគេចខ្លួនបាត់ឬកុំឲ្យអ្នកជាប់ចោទទៅគុបគិតនឹងសាក្សីឬបំបាត់កស្តុតាងបានក្នុងពេលដែលស៊ើបសួរ ។

ការឃុំឃាំងដោយមានដីកាតុលាការនេះ ច្បាប់គ្មានកំណត់ថាដល់ពេលយូរប៉ុណ្ណាត្រូវបើកលែងទេ ស្រេចតែលើចៅក្រមៗ តែចៅក្រមអាចដោះឲ្យនៅក្រៅឃុំបាន សំរាប់មនុស្សណាទើបនឹងត្រូវចោទតែមួយដងដែលគួរត្រូវទោសត្រឹមតែជាបទមជ្ឈិមថ្នាក់ទីមួយនោះ ច្បាប់ប្រណីឲ្យចាប់មកឃុំបានត្រឹមតែបីថ្ងៃរួចឲ្យបើកលែងនៅក្រៅឃុំ តែបើបទល្មើសនៃអ្នកត្រូវចោទនោះជាបទមជ្ឈិមដែលធ្ងន់ជាក់ស្តែង ច្បាប់ក៏មិនប្រណីដូច្នេះដែរ (មាត្រា ១៨៨.ក.ព.ព ) ។

ឯដីកានាំខ្លួន ដែលបានអធិប្បាយរួចមកហើយនោះមិនមែនបើកអំណាចឲ្យឃុំឃាំងបានទេ គឺគ្រាន់តែឲ្យចាប់ខ្លួនបញ្ជូនទៅតុលាការប៉ុណ្ណោះ ។

ប្រការ ៥.– នរណាចាប់ឬឃុំឃាំងគេខុសពីច្បាប់ ត្រូវទទួលទោសយ៉ាងណាខ្លះ ។

ជនណាចាប់មនុស្សទៅឃុំឃាំងហើយឃាត់ខ្លួនដោយគ្មានបង្គាប់អំពីរាជការត្រឹមត្រូវតាមច្បាប់ ហើយក្រៅពីបទល្មើសជាឧក្រិដ្ឋឬមជ្ឈិម ដែលកាន់ជាក់ស្ដែង ជននោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ បើការឃុំឃាំងមិនយូរលើសពី ១០ ថ្ងៃ ។ បើការឃុំឃាំងយូរលើសពី ១០ ថ្ងៃ ត្រូវដាក់ទោសមជ្ឈិមថ្នាក់ទី ៣ ( មាត្រា ៤៨២ .ក.៣ ) បើជនដែលឃុំឃាំងគេនោះមិនថែទាំឬបង្អត់អាហារអ្នកជាប់ឃុំថែមទៀតផង ត្រូវធ្វើទោសជននោះយ៉ាងធ្ងន់បំផុតតាមថ្នាក់ខាងលើនេះ ឬ នឹងធ្វើទោសតាមថ្នាក់ធ្ងន់ទៅទៀតក៏បាន ( មាត្រា ៤៨២-ក ៣ ) ជនណាឲ្យគេហដ្ឋនដោយចេតនាដើម្បីឲ្យគេឃុំឃាំងមនុស្សទោះឥតយកឈ្នួលក្ដី ទោះយកឈ្នួលក្ដី ជននោះត្រូវទទួលដូចអ្នកឃុំឃាំងគេនោះដែរ ( មាត្រា ៤៨៦ ក.៣ ) ។

តុលាការណាចេញបង្គាប់ឲ្យឃុំឃាំងមនុស្សដែលគ្មានត្រូវចោទជាបទឧក្រិដ្ឋឬមជ្ឈិម ហើយដែលគ្មានត្រូវកាត់ទោសអាជ្ញាឬទោសរដ្ឋប្បវេណីបង្ខំដល់រាងកាយទេ តុលាការនោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ មាត្រា ២៤៩ ក.៣ ។

ក្រៅពីតុលាការមុខក្រសួង បើមន្ត្រីឬអ្នកតំណាងរាជការចេញបង្គាប់ឲ្យចាប់មនុស្សទៅឃុំឃាំង មន្ត្រីឬអ្នកតំណាងរាជការនោះ ត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ មាត្រា ( ២៤៨ ក-៣- ) ។

ជនណាជានាយកឬជាអ្នករក្សាគេហដ្ឋានសំរាប់ឃុំឃាំងទទួលមនុស្សយកទៅឃុំឃាំងដោយឥតមានដីកាតុលាការ ឬឥតសេចក្តីស្រេច-សាលក្រមដែលតុលាការបានចេញឲ្យជននោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ ( មាត្រា ២៥០ ក-ព ) ។

ជនណាត្រូវគេក្លែងក្លាយប្តឹងតុលាការ ជាប់ទោសក្រិដ្ឋឬមជ្ឈិមដោយឥច្ឆាព្យាបាទ កាលតុលាការរកទៅមិនឃើញដូចបណ្តឹងក៏កាត់សេចក្តីលែងរួចឬលើកលែងទោសប្រកាន់ ជននោះអាចប្តឹងយកអ្នកដើមបណ្តឹងទុច្ចរិតឲ្យត្រូវទោសមជ្ឈិមថ្នាក់ទី ២ បាន ( មាត្រា ៥១៤ ក-ព ) ។

## មេសូត្រតំមាត់

( សំរាប់គ្រប់ថ្នាក់ )

### ១ - ចូរស្នេហាចំពោះញាតិសន្តាន

ហៃសិស្សទាំងឡាយ ឪពុកម្តាយ មាមីងដូនតា បងប្អូនប្រុសស្រី ចូរអ្នករាល់គ្នា តាំងចិត្តមេត្តា ស្នេហាទាំងអស់ ។ កំហុសតិចតួច កុំចងចិត្តកួច ប្រកាន់ឲ្យសោះ គោរពកោតខ្លាច អាចល្បីកេរ្តិ៍ឈ្មោះ មនុស្សម្នាទាំងអស់ សឹងសរសើរហោង ។

ពាក្យពន្យល់.= ស្នេហា =(ម.ថ. ស្នេហា) សេចក្តីស្រឡាញ់

## ២ - ត្រូវគោរពច្បាប់

ការសុខក្សេមក្សាន្ត ចំរើនធនធាន ឬវឌ្ឍការ ព្រោះអ្នកប្រកាន់តាមច្បាប់មាត្រា គោរពទុកជា កិច្ចយ៉ាងសំខាន់ ។ ការព្រមព្រៀងគ្នា រាប់អានស្នេហា យូរយារព្រោះកាន់ តាមច្បាប់ក្រិត្យក្រម ឧត្ដមសំខាន់ កិច្ចដែលជាក់ស្បាន់ ប្រកាន់ទុកហោង ។

ពាក្យពន្យល់.= ធនធាន =(ម-ថធន់ធាន) ទ្រព្យសម្បត្តិ ។

ស្បាន= ប្រាកដ, ស្ដែង, ច្បាស់ ។

## ៣ - ត្រូវមានមេត្តាដល់មនុស្សពិការ

មនុស្សទុព្វលភាព កម្លាំងដុនដាប ខ្វិនខ្វន់ជើងដៃ អន្ធបង្គុ លំបាកពេកក្រៃ ចាំងយប់ចាំងថ្ងៃ ពុំដែលសប្បាយ ។ ហេតុនេះបួរអ្នក ត្រិះរិះឱ្យជាក់ រិះរេឱ្យឆ្ងាយ កុំត្រាប់ចំអក ដោយពាក្យដោយកាយ កុំបំមើលងាយ មនុស្សពិការ ។

ពាក្យពន្យល់.= ទុព្វលភាព= (ម.ថ.ទុព្វលៈភាព)

ភាពជាអ្នកមានកម្លាំងថយ ។

ពិការៈដែលខូចអវយវៈ ។

អន្ធបង្គុៈ (ម.ថ.អន្ធៈបង្គុ) ក្ញែកខ្វាក់ ។

## ៤ – កិរិយាជាទីស្រឡាញ់នៃជនគ្រប់គ្នា

អ្នកចេះវិជ្ជាសាស្ត្រ ប្រសើរណាស់ពេកកន្លង ដេកដើរឥតមានធ្គង វាចាផងក៏ពិរោះ ។ ចិត្តសោតក៏ស្លូតត្រង់ ពុំដែលលង់គំនិតហួស ពាក្យពេចន៍គួរស្រណោះ អ្នកនោះឯងគេស្រឡាញ់ ។

បើគ្រាន់តែចេះទេ មិនចេះគ្នេរពាលឯងអញ មនុស្សនោះគេសែនក្នាញ់ មិនស្រឡាញ់បែរជាស្អប់ ។

ពាក្យពន្យល់.– គ្នេរ = គិតលៃលក ។ ក្នាញ់ = មិនស្រួលចិត្ត ។

## ៥– មនុស្សយើងត្រូវជួយធុរៈគ្នាទៅវិញទៅមក

សុខទុក្ខកើតដល់មនុស្ស ទាំងស្រីប្រុសគ្រប់ៗប្រាណ ពុំដែលជៀសវាងបាន ជួនក្សេមក្សាន្តជួនទុក្ខភ័យ ។ បើទុក្ខកើតកាលណា សែនវេទនាលំបាកក្រៃ គួរតែយើងពួតដៃ ទាំងប្រុសស្រីជួយសម្រាល ។ បើសិនមានរោគបៀត ត្រូវខ្មីឃ្មាតអភិបាល លុះតែស្រាន្តបានស្រាល គង់មានកាលគេតបគុណ ។

ពាក្យពន្យល់.= អភិបាល = រក្សា ។

រោងពុម្ពខ្មែរ